CSC
Formation, Dialogue, Cooperation

# អ្នកនាំសារ
The Messenger

កាសែតចេញផ្សាយប្រចាំខែធ្នូ ឆ្នាំទី៤ ថ្ងៃទី០១-៣១ ខែធ្នូ ឆ្នាំ២០១០ លក់តម្លៃ ១០០០រៀល តែប៉ុណ្ណោះ លេខ ៤០

## មាតិកា



យុវជនគាំទ្រផែនការវិនិយោគទឹក..
ទំព័រ ៥



អ្នកជំនាញ : មួយជាមគ្គុទេសក៍ និង ជាសម្បត្តិ...
ទំព័រ ៩



អ្នកថតរូបវ័យក្មេង : រូបថត គឺជាសិល្បៈ
ទំព័រ ១៧

# ស្ត្រីគឺជាឆ្អឹងខ្នងនៃការអភិវឌ្ឍ ប៉ុន្តែ សមភាពភេទនៅមានតែគម្លាតឆ្ងាយ



ការអភិវឌ្ឍប្រទេសជាតិមួយត្រូវការបញ្ញាញាណពីធនធានមនុស្សគ្រប់ៗរូប។ ក្នុងនោះការចូលរួមរបស់ស្ត្រីក្នុងភាពជាអ្នកដឹកនាំ សហគ្រាស ឬស្ថាប័នណាមួយពិតជានាំមកនូវការប្រែប្រួលរីកចម្រើនដ៏ពិតប្រាកដដល់ទីកន្លែងនោះ ដោយសារទោះបីជាស្ត្រី មានកម្លាំងទន់ខ្សោយជាងបុរស ប៉ុន្តែគេមានបញ្ញាមិនចាញ់គ្នាឡើយ។ ទំព័រទី១០_១១

កម្មវិធី ពន្លកថ្មី ជាកម្មវិធីវិទ្យុថ្មីមួយរបស់
ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក។
កម្មវិធីនេះផ្តោតលើពលកម្មកុមារ និងបញ្ហាការកេងប្រវ័ញ្ច
លើកុមារ ដែលសហការជាមួយវិទ្យុសម្លេងប្រជាធិបតេយ្យ
VOD មានផ្សាយនៅរាល់ ថ្ងៃច័ន្ទ ម៉ោង ៤-៥ រសៀល
ផ្សាយនៅ FM 106.5 MHz ។




អេម៉ានូអែល សំឡេងពីព្រះសហគមន៍កាតូលិក !
ភ្នំពេញ : FM 102.5 Mhz ម៉ោង២:០០-៣:០០ រាល់រសៀលថ្ងៃសុក្រ
បាត់ដំបង : FM 91.0 Mhz ម៉ោង ៧:៣០-៨:៣០ រាល់យប់ថ្ងៃសៅរ៍
សៀមរាប: FM 102.5 Mhz ១០:០០-១១:០០ រាល់ថ្ងៃសៅរ៍
កំពង់ធំ : FM 88.5 Mhz ម៉ោង ១២:៣០-១:៣០ ថ្ងៃសៅរ៍ថ្ងៃត្រង់
កំពង់ចាម : FM 100.5 Mhz ម៉ោង ៦:៣០-៧:០០ យប់ថ្ងៃអាទិត្យ
ក្រុងព្រះសីហនុ : FM 107.5 Mhz ម៉ោង៥:០០-៦:០០ រសៀលថ្ងៃសៅរ៍
កំពត : FM 93.25 Mhz ម៉ោង ៥:០០-៦:០០ រសៀលថ្ងៃសៅរ៍

# រូបថតប្រចាំខែ



Photo : S. Philong

ទិដ្ឋភាពនៅលើស្ពានកោះពេជ្រក្រោយឧបទ្ទវហេតុការផ្អើលជាន់គ្នា នៅថ្ងៃទី២២ វិច្ឆិកា ដែលបណ្តាលអោយមនុស្ស ៣៥៣ស្លាប់ និងរាប់រយនាក់ទៀតរងរបួស។



Photo : Nith

ព្រះសង្ឃ តាជីយាយជីព្រមទាំងពុទ្ធបរិស័ទយ៉ាងច្រើនកុះករ ដង្ហែក្បួនគោរពវិញ្ញាណក្ខន្ធអ្នកស្លាប់នៅស្ពានកោះពេជ្រ។



Photo : Nith

ទាំងគ្រីស្តបរិស័ទ ទាំងពុទ្ធបរិស័ទ និងមនុស្សម្នាទូទៅអុជធូប គោរពវិញ្ញាណក្ខន្ធដល់អ្នកស្លាប់ក្នុងឧបទ្ទវហេតុលើកស្ពានកោះពេជ្រ។



Photo : S. Philong

ក្រុមសមត្ថកិច្ចកំពុងប្រញាប់ប្រញាល់លើកជនរងគ្រោះដើម្បីយកទៅមន្ទីរពេទ្យមួយចំនួនដូចជា មន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត មន្ទីរពេទ្យកាល់ម៉ែត្រ និងព្រះកុសមៈ...ដែលរង់ចាំទទួលជនរងគ្រោះក្នុងហេតុការណ៍បន្ទាន់នោះ។



Photo : Nith

លោកបូជាចារ្យ ប៉្រយណូ កូសម៉ី នាំអំណោយនៃព្រះសហគមន៍កាតូលិកជូនជនរងរបួសលើស្ពានពេជ្រ។

# សារលិខិតលោកអភិបាលព្រះសហគមន៍កាតូលិក

# តើអ្នករាល់គ្នាទៅវាលរហោស្ថានរកមើលអ្វី?

**ភ្នំពេញ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០**

**លេខ ១៨,២០១០-អភ**

ជូនចំពោះបងប្អូនជាទីស្រលាញ់

"តើអ្នករាល់គ្នាទៅវាលរហោស្ថានរកមើលអ្វី? រកមើលដើមត្រែង ដែលត្រូវខ្យល់បក់នោះឬ? តើអ្នករាល់គ្នាទៅរកមើលអ្វី? រកមើលមនុស្សស្លៀកពាក់ល្អរុងរឿងឬ? តាមធម្មតាអស់អ្នកស្លៀកពាក់ល្អរុងរឿងគេរស់នៅក្នុងដំណាក់ស្តេចឯណោះ។ បើដូច្នេះ តើអ្នករាល់គ្នាទៅរកមើលអ្វី? ទៅរកមើលព្យាការីម្នាក់ឬ"(សូមមើលម៉ាថាយ១១,៧-៩ ត្រូវជាអត្ថបទគម្ពីរសប្តាហ៍ទី៣ នៃរដូវរង់ចាំ)។

សំនួរអំពីលោកយ៉ូហានដែលព្រះយេស៊ូសួរសាវ័ក គឺជាសំនួររបស់ព្រះយេស៊ូមកយើងនៅពេលចាប់ផ្តើមរដូវរង់ចាំនេះ។

តើអ្នករាល់គ្នាទៅវាលរហោស្ថានរកមើលអ្វី ?

បួនសប្តាហ៍ខាងមុខ គឺជួយយើងទាំងអស់គ្នាពិចារណាពីចិត្តគំនិតខ្លួនឯងនឹងស្វែងរកព្រះយេស៊ូ។

តើព្រះយេស៊ូជានរណា? តើព្រះអង្គជាដើមត្រែងដែលត្រូវខ្យល់បក់? ឬជាបុរសម្នាក់នៅវាលរហោស្ថានដែលមានសម្លៀកបំពាក់ដ៏ប្រណិត? ឬជាព្យាការីម្នាក់?

អត្ថបទព្រះគម្ពីរក្នុងអាទិត្យទី៤គឺឆ្លើយតប និងសំនួររបស់យើង : "មើល! ស្ត្រីព្រហ្មចារីនឹងមានផ្ទៃពោះនាងនឹងសម្រាលបានបុត្រមួយដែលគេនឹងថ្វាយព្រះនាមថា "អេម៉ានូអែល" ប្រែថា "ព្រះជា ម្ចាស់គង់នៅជាមួយយើង" ( សូមមើលម៉ាថាយ ១,២៣ ត្រូវជាអត្ថបទគម្ពីរសប្តាហ៍ទី៤)។

ឱ! ព្រះយេស៊ូអើយ! ព្រះអង្គមិនមែនជាដើមត្រែងដែលត្រូវខ្យល់បក់នោះទេ។ ព្រះអង្គមិនមែនជាអ្នកមាន ឬជាព្យាការីនោះទេ។ ព្រះអង្គជាទារកមួយ ហើយជាព្រះបុត្រារបស់ព្រះជាម្ចាស់ផ្ទាល់។ ព្រះអង្គជា "អេម៉ានូអែល" ព្រះអង្គជាព្រះជាម្ចាស់គង់ នៅជាមួយយើង។

ក្នុងរដូវរង់ចាំនេះព្រះបន្ទូល អញ្ជើញយើងទាំងអស់គ្នាឱ្យរៀបចំខ្លួនទទួលព្រះអម្ចាស់យេស៊ូដែលយាងមកគង់ជាមួយយើងរាល់គ្នា(សូមមើល ម៉ាថាយ ២៤,៤៤ ត្រូវជាអត្ថបទគម្ពីរនៃសប្តាហ៍ទី១)។

ដើម្បីរៀបចំផ្លូវថ្វាយព្រះជាម្ចាស់ យើងត្រូវតែរៀបចំចិត្តគំនិតរបស់យើង (សូមមើល ម៉ាថាយ ៣,៣ ត្រូវជា អត្ថបទគម្ពីរនៃសប្តាហ៍ទី២)។

តើអ្នករាល់គ្នាទៅវាលរហោស្ថានរកមើលអ្វី?

វាលរហោស្ថាន គឺជាទីកន្លែងដែលស្ងាត់ជ្រងំបំផុត។

ចូរយើងទាំងអស់គ្នាចំណាយពេលវេលាអានព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅផ្ទះ ឬនៅព្រះវិហារ។

ចូរយើងរៀបចំការអធិដ្ឋានតាមព្រះសហគមន៍នានា ដើម្បីចាយពេលវេលាជាមួយព្រះជាម្ចាស់ដោយស្ងៀមស្ងាត់។ នៅពេលវេលានេះ ព្រះជាម្ចាស់អាចមានព្រះបន្ទូលមកយើង តើយើងទាំងអស់គ្នាកំពុងស្វែងរកអ្វី ?

ចូរឱ្យយើងចេះចំណាយពេលវេលាដើម្បីទទួលអគ្គសញ្ញាលើកលែងទោស។

ចូរយើងរៀបចំចិត្តគំនិតដើម្បីធ្វើជាសាក្សីរបស់ព្រះយេស៊ូដល់អ្នកដទៃ ជាពិសេសដល់អស់អ្នកដែលមិនទាន់ស្គាល់ព្រះអង្គ។

យើងស្វែងរកព្រះយេស៊ូ ក៏ប៉ុន្តែព្រះអង្គគង់នេះជាមួយយើងរួចហើយ។ ព្រះអង្គគង់នៅក្នុងចិត្តយើង ព្រះអង្គគង់នៅជាមួយយើងគ្រប់ពេលវេលា។ ពេលយើងមានអំណរសប្បាយ ក៏ព្រះអង្គគង់នៅជាមួយយើង ពេលយើងសេចក្តីសង្ឃឹម ក៏ព្រះអង្គគង់នៅជាមួយយើង និងពេលយើងជួបទុក្ខលំបាក ក៏ព្រះអង្គគង់នៅជាមួយយើងដែរ។

ព្រះវិញ្ញាណដ៏វិសុទ្ធណែនាំយើងឱ្យយល់ច្បាស់ថា ព្រះជាម្ចាស់គង់ជាមួយយើងពិតមែន។

ក្នុងអំឡុងពេលបុណ្យព្រះយេស៊ូប្រសូតខាងមុខនេះ យើងនឹងមានអំណរសប្បាយជាមួយអស់អ្នកគង្វាល និង ទេវទូត ពីព្រោះយើងដឹងថា ព្រះជាម្ចាស់គង់ជាមួយយើងពិតមែន។

យើងអាចជូនព្រះយេស៊ូដល់បងប្អូន ក្នុងឱកាសបុណ្យព្រះយេស៊ូប្រសូតនិងពេញមួយឆ្នាំនាពេលខាងមុខនេះ ដូចព្រះនាងម៉ារីដែលបានផ្តល់ព្រះយេស៊ូជាអំណោយដល់ពិភពលោកទាំងមូល។

សូមបងប្អូនទទួលនូវសេចក្តីស្រឡាញ់រាប់អានដ៏ខ្ពង់ខ្ពស់ស្មោះស្ម័គ្រអំពីខ្ញុំ។

សូមព្រះជាម្ចាស់ប្រទានពរដែលបងប្អូនទាំងអស់គ្នា។

**សុខកុមារ អូលីវីយេ ឝ្មីតអីស្នែរ**

**លោកអភិបាលរបស់បងប្អូន**


**ការិយាល័យព័ត៌មានកាតូលិក**

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់បឹងព្រលិត ខណ្ឌ ៧ មករា រាជធានី ភ្នំពេញ

Tel/Fax : (855) 23 224 120;

E-mail : csccambodia@gmail.com

Website : www.catholiccambodia.org

អ្នកសម្របសម្រួល : លោកស្រីប្រាម៉ុង វីរជ័យ។ ប្រធាន : លោកលី សុវណ្ណា។

Licence ១៨៣ ពម.ប្រក. / ២៥-មិថុនា-២០០៧

# សេដ្ឋកិច្ច

## សហគ្រាសខ្នាតតូចនិងមធ្យមនៅកម្ពុជាផ្តល់ការងារ១,៤លាននាក់

**ខាន់ ភីរម្យ**



Photo : Rithy

លោកតែ តាំងប៉រ ប្រធានសមាគមសហគ្រាសធុនតូច និងមធ្យមកម្ពុជាបានឱ្យដឹងថា វិស័យសហគ្រាសធុនតូច និងមធ្យមក្នុងប្រទេសកម្ពុជាកំពុងដើរតួយ៉ាងសំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ច និងទីផ្សារកម្លាំងពលកម្ម។

យោងតាមតួលេខរបស់សមាគមសហគ្រាសធុនតូច និងមធ្យមកម្ពុជាបានឱ្យដឹងថា បច្ចុប្បន្ននេះ បណ្តាសហគ្រាសខ្នាតតូច និងមធ្យមដែលផ្តល់ការងារធ្វើដល់មនុស្សពី១នាក់ ទៅដល់១០នាក់ មានចំនួន ៣០៧០០០សហគ្រាស ហើយសហគ្រាសដែលផ្តល់ការងារដល់មនុស្សពី ១១នាក់ ទៅដល់ ១០០នាក់ មានចំនួន១៣១២៣សហគ្រាស។ ជាសរុបកម្លាំងពលកម្មដែលកំពុងបម្រើការនៅក្នុងផ្នែកនេះ មានចំនួនប្រមាណ ១,៤ លាននាក់។

លោកតែ តាំងប៉រ បានឱ្យដឹងថា បណ្តាសហគ្រាសធុនតូច និងមធ្យមនៅមានផលិតភាពទាបការចំណាយក្នុងផលិតកម្មខ្ពស់។ បញ្ហាទាំងនេះ គឺដោយសារតែកង្វះពតិមានអំពីទីផ្សារ និងគ្រឿងចក្រជាដើម ហើយកត្តាដែលសំខាន់ជាងនេះគឺកង្វះខាតដើមទុន។ លោកតាំងប៉របន្តថា ដើម្បីពង្រីកប្រតិបត្តិការអាជីវកម្មប្រភពទុនគឺមិនខ្វះទេ។ ប៉ុន្តែ សហគ្រិនខ្វះខាតនូវលទ្ធភាពក្នុងការទទួលបាននូវឥណទានក្នុងអត្រាការប្រាក់សមរម្យ។

លោកស្រី អ៊ុក ម៉ាលី អគ្គទេសាភិបាលរងធនាគារជាតិកម្ពុជា បានទទួលស្គាល់ថា នេះគឺជាបញ្ហាដែលបណ្តាសហគ្រិនខ្នាតតូច និងមធ្យមទាំងអស់កំពុងតែប្រឈម។ លោកស្រីម៉ាលីបានឱ្យដឹងថា កង្វះប្រភពហិរញ្ញប្បទានពិតជាមិនអាចផ្តល់លទ្ធភាពឱ្យសហគ្រាសខ្នាតតូច និងមធ្យមអភិវឌ្ឍរីកចម្រើនទៅមុខបានទេ។ លោកស្រី ក៏ បានបន្តថា : "គិតត្រឹមឆមាសទី១ ដើមឆ្នាំ ទំហំឥណទានសរុបមានតម្លៃ ៣៨៧០លានដុល្លារ មានអតិថិជនប្រមាណ ១,២លាននាក់ ទទួលបាន។ ទោះជាទំហំឥណទានសម្រាប់ផ្គត់ផ្គង់ដល់សហគ្រាសធុនតូច និងមធ្យមនៅមានកម្រិតនៅឡើយ"។

ឯកឧត្តមស៊ុយ សែម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល មានប្រសាសន៍ថា នៅទូទាំងប្រទេសកម្ពុជា មានសហគ្រាសអាជីវកម្មទាំងអស់ទាំងចុះបញ្ជី និងមិនចុះបញ្ជីសរុបចំនួន៣៧៥០៩៥ នៅក្នុងនោះ ជាង ៩០% នៃ សហគ្រាសទាំងអស់នោះគឺប្រើប្រាស់ថវិកាផ្ទាល់ខ្លួន ឬកម្ចីពីគ្រួសារនិងមិត្តភក្តិដើម្បីចាប់ផ្តើមអាជីវកម្ម និងជំរុញដំណើរការអាជីវកម្ម។

### ស្ថាប័នហិរញ្ញវត្ថុ និងបញ្ហាឥណទាន

លោកស្រីសូ ផលណារី នាយករងប្រតិបត្តិនៃធនាគារអេស៊ីលីដា បានឱ្យដឹងថា ឥណទានគឺជា សេវាកម្មដ៏ចម្បងរបស់បណ្តាស្ថាប័នធនាគារ និងហិរញ្ញវត្ថុទាំងអស់។ ប៉ុន្តែស្ថាប័នទាំងនោះត្រូវការនូវនិរន្តរ៍ភាពរបស់ខ្លួនផងដែរ។

លោកស្រីប្រាប់ថា សព្វថ្ងៃកម្ពុជាមានធនាគារពាណិជ្ជសរុបចំនួន២៨ ធនាគារឯកទេសចំនួន ៦ ដែលមានការិយាល័យសរុបទាំងអស់ចំនួន ៣៩៩កន្លែង និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន២២ជាមួយនិង ការិយាល័យ ប្រតិបត្តិចំនួន ៥០៥កន្លែង ដែលកំពុងផ្តល់សេវាកម្មឥណទានដល់អតិថិជន។ ប៉ុន្តែ ដើម្បីធានានូវនិរន្តរភាពរបស់ខ្លួន សេវាកម្មឥណទានដែលផ្តល់ជូនដល់អតិថិជនតែងតែផ្អែកលើការវិនិច្ឆ័យផ្ទាល់ខ្លួន និងទំនុកចិត្តគ្នាទៅវិញទៅមក។

# សុខភាព

## ការបរិភោគអាហារត្រឹមត្រូវគឺចាំបាច់សម្រាប់រាងកាយ

**ជាត សំភី**



Photo :DR

ជាធម្មតាមនុស្សយើងត្រូវការថាមពលពី ២០០០ ទៅ២៥០០ គីឡូកាឡូរីក្នុងមួយថ្ងៃ ពីអាហារបរិភោគប្រចាំថ្ងៃ។

តាមប្រសាសន៍របស់លោកវេជ្ជបណ្ឌិត ហែម សុខហន នៃមន្ទីរពេទ្យកុមារជាតិ បានឱ្យដឹងថា មនុស្សយើងត្រូវការ បរិភោគអាហារបីពេលក្នុងមួយថ្ងៃ។ ដូច្នេះអ្វីដែលយើងធ្វើ គឺបំពេញថាមពលដែលរាងកាយយើងត្រូវការដើម្បី ទ្រទ្រង់សុខភាព និងរាងកាយឱ្យបានរឹងមាំ។

លោកវេជ្ជបណ្ឌិតបន្តថា យើងគួរបរិភោគឱ្យមានតុល្យភាព។ ក្នុងមួយពេលយើងគួរមានបាយ បន្លែគ្រប់មុខ និង សាច់ ពីព្រោះរាងកាយ យើងត្រូវការអាហារបីក្រុម។ ក្រុមទី១ គឺអាហារ សាងសង់ មាននៅក្នុងសាច់សត្វដូចជា សាច់គោ សាច់ជ្រូក មាន់ទា-ល-។ ទី២ អាហារថាមពលមាន បាយ ដំឡូង ពោត សណ្តែក-ល-។ ទីបី គឺអាហារការពារ មានដូចជា បន្លែគ្រប់មុខ។

លោកវេជ្ជបណ្ឌិតបន្តទៀតថា ការបរិភោគមិនត្រឹមត្រូវធ្វើឱ្យប៉ះពាល់សុខភាពរាងកាយ។ ប្រសិនបើយើងបរិភោគខ្លាញ់ឬស្ករច្រើនលើសលប់ពេកវាអាចធ្វើឱ្យយើងលើសឈាម ឬមានជំងឺទឹកនោមផ្អែម។ ផ្ទុយទៅវិញ បើសិនជាយើង បរិភោគអាហារមិនគ្រប់គ្រាន់ធ្វើឱ្យយើងមានរាងកាយមិនមាំមួន និងមានរូបរាងឆាប់ចាស់។ម្យ៉ាងទៀតបើសិនមានមេរោគបៀតបៀន គឺអ្នកបរិភោគមិនគ្រប់គ្រាន់ដូចជាខ្វះជាតិបន្លែងាយឆ្លងជំងឺណាស់។

លោកវេជ្ជបណ្ឌិតហែម សុខហន សង្កត់ធ្ងន់ថា : "បរិភោគអាហារដើម្បីសុខភាពល្អមិនមែនតែអាហារថ្លៃទេសំខាន់គឺ ការបរិភោគគ្រប់គ្រាន់ និងធ្វើឱ្យមានតុល្យភាពអាហារទាំង៣ក្រុម "។



Photo : S. Philong

# យុវជនគាំទ្រផែនការវិនិយោគទឹកប្រាក់ ១៦០០លាន ដុល្លាររបស់ចិន

**ខាន់ ភីរម្យ**

ក្រោយពេលដែលប្រធានសភាចិន ប្រកាសអំពីគម្រោងផែនការវិនិយោគនៅក្នុងប្រទេសកម្ពុជា ដែលមានទឹកប្រាក់ រហូតដល់ទៅ១៦០០លាន-ដុល្លារ ក្នុងរយៈពេលពីឆ្នាំ២០១០ ដល់២០១៥ នោះក្រុមយុវជនកម្ពុជាគាំទ្រ ហើយអះអាងថា នេះគឺជាប្រភពផ្ដល់ការងារមួយដ៏ចម្បង។

លោកឃឹម ចាន់ថា អាយុ ២៦ឆ្នាំ ប្រជាពលរដ្ឋមួយរូបបានឱ្យដឹងថា នេះគឺជាពត៌មានដ៏ល្អសម្រាប់ប្រទេសកម្ពុជា និងសម្រាប់យុវជន ដែលចម្រើនវ័យត្រូវចូលទៅរកការងារធ្វើ។ លោកបានបញ្ជាក់ថា : "នេះគឺជាផែនការវិនិយោគ ដ៏ធំហើយ ខ្ញុំសង្ឃឹមថា វានឹងបង្កើតការងារធ្វើ ដល់ប្រជាជនខ្មែររាប់ពាន់នាក់ ខណៈពេលដែលកម្ពុជា នៅមានយុវជនជាច្រើនដែលពុំទាន់មានការងារធ្វើនោះ"។

លោកថេង វ៉ាន់ស័ក្ក និស្សិតឆ្នាំទី៤ ផ្នែកសង្គមវិទ្យា នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញបានឱ្យដឹងថា : "នេះគឺជា គម្រោងវិនិយោគដែលធំ ហើយវាចំពេលដែលខ្ញុំនឹងបញ្ចប់ការសិក្សាល្មម។ ខ្ញុំរំពឹងថាអាចនឹងទទួលបានការងារធ្វើ ពីគម្រោងទាំងនេះ។ លោកបានបន្តទៀតថា ធម្មតាប្រសិនបើគម្រោងនេះនឹងត្រូវចាប់ផ្តើមមែននោះវានឹងបង្កើតទីផ្សារការងារមួយដ៏ធំសម្រាប់យើងជាយុវជនដែលកំពុងតែស្រេកឃ្លានការងារ។ លោកបានបញ្ជាក់ថា : "ទឹកប្រាក់ ១៦០០លានដុល្លារគឺ ធំណាស់ "។

លោកសន វុត្ថា និស្សិតឆ្នាំទី៤ ជំនាញអភិវឌ្ឍន៍ជនបទនៃសកលវិទ្យាល័យភូមិន្ទកសិកម្មបានឱ្យដឹងថា ប្រសិនបើ ចិនវិនិយោគមែននោះវាគឺជាគម្រោងវិនិយោគដ៏ធំនៅក្នុងប្រទេសកម្ពុជា ដែលនឹងទទួលបាននៅក្នុងរយៈពេល៥ឆ្នាំខាងមុខនេះ។

តាមការអះអាងរបស់វុត្ថាបានឱ្យដឹងថា បើទោះបីជាគម្រោងវិនិយោគនេះហាក់ដូចជាមិនសូវចំនឹងអ្វីដែលខ្លួន កំពុងតែសិក្សាមែន តែវាយ៉ាងហោចណាស់ ក៏នឹងផ្តល់ការងារធ្វើដល់បងប្អូននិងមិត្តភក្តិរបស់លោកផងដែរ។ វុត្ថា បានបញ្ជាក់ថា : "តាមខ្ញុំដឹង ចិនភាគច្រើនគាត់វិនិយោគលើតែផ្នែកឧស្សាហកម្ម និងថាមពល ដូចជាវារីអគ្គិសនីជាដើម តែខ្ញុំសិក្សាខាងអភិវឌ្ឍន៍ជនបទមើលទៅដូចជាមិនសូវត្រូវ តែខ្ញុំក៏សប្បាយចិត្តដែរក្រែងពេលចប់ គេមានកន្លែងមួយសម្រាប់ខ្ញុំដែរ ពីព្រោះ ១៦០០លានដុល្លារទឹកប្រាក់ច្រើនណាស់"។

គម្រោងទឹកប្រាក់វិនិយោគនេះ គឺធ្វើឡើងនៅក្រោយពេលដែលលោកវូ បានហ្គោ (Wu Bang guo) ប្រធានរដ្ឋសភាចិនមកបំពេញទស្សនកិច្ចកាលពីដើមខែវិច្ឆិកាកន្លងទៅ។

លោកខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងពត៌មាន និងជាអ្នកនាំពាក្យរបស់រាជរដ្ឋាភិបាលកម្ពុជា បានមានប្រសាសន៍ប្រាប់អ្នកសារពត៌មាននៅក្នុងសន្និសីទសារពត៌មានមួយថា គម្រោងផែនការវិនិយោគដែលមានទឹកប្រាក់សរុបចំនួនរហូតដល់ទៅ ១៦០០ លានដុល្លារ នឹងត្រូវវិនិយោគលើគម្រោងចំនួន២៣ ពីឆ្នាំ២០១០ ដល់ឆ្នាំ២០១៥។

ទន្ទឹមនឹងសេចក្តីសង្ឃឹម ក៏ក្រុមយុវជនកម្ពុជាសម្តែងការព្រួយបារម្ភខ្លះៗចំពោះគម្រោងទាំងនេះជាពិសេសគឺ ផលប៉ះពាល់បរិស្ថាននិងសង្គម។

លោកឃឹម ចាន់ថា បានឱ្យដឹងថា : "ខ្ញុំព្រួយបារម្ភថា គម្រោងទាំងនេះប៉ះពាល់ទៅដល់បរិស្ថាន និងធនធានធម្មជាតិ"។ លោកបានបញ្ជាក់ថា : "នេះគឺជាគម្រោងដ៏ធំ ហើយខ្ញុំរំពឹងថា នឹងបង្កើតឱកាសការងារច្រើន ដល់យុវជនយើង។ ប៉ុន្តែខ្ញុំព្រួយបារម្ភថា គម្រោងទាំងនេះអាចនឹងធ្វើឱ្យ ប៉ះពាល់ទៅដល់រ៉ែ ព្រៃឈើ និងធនធានធម្មជាតិដែលមាននៅក្នុងប្រទេសយើង"។

លោកវ៉ាន់ស័ក្ក បានឱ្យដឹងថា គ្រប់គម្រោង និង សកម្មភាពរបស់មនុស្សទាំងអស់តែងតែមានផលប៉ះពាល់ ដូច្នេះយើងរំពឹងថា គម្រោងទាំងនេះនឹងចូលរួមកាត់បន្ថយផលប៉ះពាល់ ។

# ក្រសួងកសិកម្ម : ដំណាំរួមផ្សំឆ្នាំនេះលើសផែនការ

**ខាន់ ភីរម្យ**

ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ បាន អះអាងថា ក្រៅពីដំណាំស្រូវការបង្កបង្កើនផលលើ ដំណាំរួមផ្សំរបស់កសិករកម្ពុជានៅទូទាំងប្រទេស នាឆ្នាំ២០១០នេះ កើនឡើងប្រមាណ ៥០.២២០ ហិចតា ។


Photo : P. Samphy

យោងទៅតាមរបាយការណ៍មួយរបស់ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានឱ្យដឹងថា ការអនុវត្តដំណាំរួមផ្សំរបស់កសិករនៅក្នុងឆ្នាំនេះ គឺមាន ប្រមាណជា ៤៦០.៨៣០ហិចតា ពោលគឺ លើសពីឆ្នាំមុន ប្រមាណជា ៥០.២២០ ហិចតា ។

របាយការណ៍ដដែលនោះក៏បានឱ្យដឹងទៀតផង ដែរថា ប្រភេទដំណាំរួមផ្សំដែលត្រូវបានកសិករ កម្ពុជាបង្កបង្កើនផលនៅក្នុងអំឡុងឆ្នាំ២០១០នេះ គឺរួមមានពោត ដំឡូងឈើ ដំឡូងជ្វា បន្លែគ្រប់មុខ និងសណ្តែកបាយ ។

ក្រសួងកសិកម្មបានឱ្យដឹងថា នៅឆ្នាំនេះកសិករ បង្កបង្កើនផលដំណាំពោត ប្រមាណ១៨៩.៩៦៨ ហិចតា តិចជាងឆ្នាំទៅប្រមាណ ៣.៥០០ហិចតា ។ ប៉ុន្តែសម្រាប់ដំណាំដំឡូងឈើវិញនោះ គឺបានចំនួន ១៨៧.១០៧ហិចតា លើសឆ្នាំទៅ ៣៧.១៧០ហិចតា ។ ដំឡូងជ្វាវិញនោះគឺ បានចំនួន ៦.៩៦៣ ហិចតា លើសឆ្នាំមុនប្រមាណជាជាង ១០០០ហិចតា ។ បន្លែគ្រប់មុខ គឺបានចំនួន ២៦.៣៤៣ហិចតា តិចជាងឆ្នាំទៅ ៤០៩ហិចតា សម្រាប់ដំណាំសណ្តែកបាយវិញនោះ គឺបានសរុបចំនួន ៥០.៤៤៩ ហិចតា ពោលគឺលើសពីឆ្នាំទៅចំនួនប្រមាណជា ១៥.៩០៩ ហិចតា ។ ក្រៅពីដំណាំរួមផ្សំចេញ ប្រភេទដំណាំកសិកម្មដែលគេចាត់ទុកថា ជាកសិឧស្សាហកម្ម ដូចជា សណ្តែកដី សណ្តែកសៀង ល្ង អំពៅ ក្រចៅ និងថ្នាំជក់ជាដើមនោះ គឺកសិករកម្ពុជាអាចបង្កបង្កើនផលបានចំនួន ១៦៧.១៩៥ហិចតា ពោលគឺ លើសពីឆ្នាំទៅ ចំនួន ១៦.៣៤៥ ហិចតា ។

ប្រភពដដែលនោះបានឱ្យដឹងថា នៅក្នុងឆ្នាំនេះ សណ្តែកដីត្រូវបានបង្កបង្កើនផលលើផ្ទៃដីមាន ចំនួនសរុប ១៥.៣៤៩ ហិចតា លើសពីឆ្នាំមុន ១,៥ ពាន់ហិចតា ។ សណ្តែកសៀងវិញនោះ គឺនៅលើផ្ទៃ ដីចំនួន ៨៩.៥៤០ ហិចតា ពោលគឺលើសពីឆ្នាំមុនចំនួនប្រមាណជា ៣,៦ហិចតា ។ ល្ងវិញនោះ គឺបានចំនួន ៤៨.២៥៣ហិចតា ពោលគឺលើសពីឆ្នាំមុនប្រមាណជា ៩ពាន់ហិចតា ។ អំពៅវិញនោះគឺ បានចំនួន ១៣.៨១៨ហិចតា ពោលគឺលើសពីឆ្នាំទៅចំនួនប្រមាណជា ២,២ពាន់ហិចតា ។

ក្រចៅវិញនោះឆ្នាំនេះគឺអនុវត្តបានត្រឹមតែ ២៣០ហិចតាទេ ពោលគឺតិចជាងឆ្នាំទៅ ១០៦ ហិចតា ។ ដោយឡែកថ្នាំជក់វិញនោះ គឺបានត្រឹមតែ ៥ហិចតាតែប៉ុណ្ណោះ ពោលគឺតិចជាងឆ្នាំមុនប្រមាណជា ៦៨ ហិចតាតែប៉ុណ្ណោះ ។

បរិស្ថាន

# សន្និសីទនៅរុស្ស៊ីស្តីអំពីការអភិរក្សសត្វខ្លាព្រៃ

យោងតាមសារព័ត៌មានស៊ីនហ្វួរបានឱ្យដឹងថា ប្រទេសចំនួន ១៣ ដែលនៅជាជម្រករបស់សត្វខ្លាព្រៃបានជួបជុំគ្នានៅទីក្រុងប៉េតេប្បូរនៃប្រទេសរុស្ស៊ីក្នុងការតាំងចិត្តធ្វើឱ្យចំនួននៃសត្វខ្លាកើនទ្វេ គឺដល់ចំនួន ៧០០០ក្បាល ពីពេលនេះរហូតដល់ ឆ្នាំ២០២២។

កិច្ចប្រជុំបានធ្វើឡើងពីថ្ងៃទី២១ ដល់ថ្ងៃទី ២៤ វិច្ឆិកា ដែលមានការចូលរួមពីធនាគារពិភពលោក មូលនិធិពិភពលោកដើម្បីធម្មជាតិប៉ុស្តទូរទស្សន៍ណេតជីអូក្រាហ្វិដែគូផ្សេងៗ ព្រមទាំងតួអង្គនៃការការពារធម្មជាតិ។

លោក រ៉ូបឺត ហ្សូអេលីក ប្រធានធនាគារពិភពលោកបានបង្ហាញថា ការបរបាញ់ ការជួញដូរខុសច្បាប់ព្រមទាំងបាត់ទីជម្រក បានរួមចំណែកធ្វើឱ្យថយចុះចំនួនសត្វខ្លាព្រៃឱ្យមកនៅត្រឹម ៣២០០ ក្បាល។ លោកហ្សូអេលីកបន្ថែមថា : "យើងត្រូវតែថែរក្សាជម្រក និងដែនដីរបស់ខ្លាដោយប្រយុទ្ធនឹងការជួញដូរខុសច្បាប់ និងលើកកម្ពស់ចំណេះដឹងថា សត្វខ្លានៅរស់នឹងមានប្រយោជន៍ច្រើនជាងសត្វខ្លាងាប់"។

តាមគេហទំព័រនៃអង្គការសត្វព្រៃពិភពលោក ជម្រកសត្វខ្លាសុទ្ធតែនៅក្នុងទ្វីបអាស៊ី។ ប្រទេសទាំងនេះព្រមព្រៀងជាគោលការណ៍ដើម្បី បង្កើនចំនួនសត្វខ្លា ក្នុងនោះមានការប្រយុទ្ធទៅនឹងការកាប់ព្រៃឈើ ការបរបាញ់ និងទីផ្សារងងឹតដែលគេឃើញមានលក់នូវសរីរាង្គរបស់សត្វខ្លា។

**ឯកសារបរទេស**


Photo : S. Phiong

# ការបោះពុម្ពស៊ីប៉ា នៅក្នុងទស្សនវិស័យនៃការធ្វើខ្លួនឱ្យទៅជាស្វយត

**ជាត សំភី**

ស៊ីប៉ាគឺជាសមាគមសាមគ្គីភាពជាអន្តរជាតិដែលធ្វើសកម្មភាពលើវិស័យអំណានដើម្បីទាំងអស់គ្នានៅកម្ពុជា។ អង្គការនេះបង្កើតដោយជនជាតិបារាំងនៃទីក្រុងវែរសៃ ប្រទេសបារាំង នៅឆ្នាំ១៩៨២។

នៅក្នុងបេសកកម្មរបស់ខ្លួនដែលជួយលើកស្ទួយការអប់រំដែលប្រកបដោយគុណភាពរបស់កុមារ និងចូលរួមប្រយុទ្ធប្រឆាំងនឹងអនក្ខរភាពតាមរយៈការលើកកម្ពស់ការអានសៀវភៅសម្រាប់ប្រជាជនខ្មែរឱ្យបានគ្រប់ៗរូបអង្គការនេះបានដាក់ចេញនូវកម្មវិធីជាច្រើន។ កម្មវិធីនីមួយៗមានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយរដ្ឋាភិបាលតាមរយៈក្រសួងអប់រំ។



Photos : Sipar

បុគ្គលិករបស់អង្គការស៊ីប៉ាំរកំពុងនិទានរឿងព្រេងឱ្យដល់កុមារៗស្តាប់ នៅពេលរថយន្តបណ្ណាល័យចល័តចុះតាមភូមិ។

ខណៈដែលអនក្ខជននៅកម្ពុជាមានប្រមាណជា២លាននាក់កម្មវិធីរបស់អង្គការស៊ីប៉ាបានរួមចំណែកយ៉ាងគួរឱ្យកត់សម្គាល់ដើម្បីចូលរួមជាមួយរដ្ឋាភិបាលក្នុងការកាត់បន្ថយចំនួននេះ។ ភាគច្រើននៃកម្មវិធីរបស់ខ្លួន អង្គការស៊ីប៉ាសុទ្ធតែជួយទៅលើវិស័យអប់រំក្នុងនោះមានការជំរុញបណ្ណាល័យនៅសាលាបឋមសិក្សា ការជំរុញបណ្ណាល័យចល័ត ការបណ្តុះបណ្តាលបណ្ណារក្ស និងការបោះពុម្ពសៀវភៅជាភាសាខ្មែរប្រកបដោយគុណភាព។

អ្នកស្រីស្តេផានី គ្រី បុគ្គលិកទំនាក់ទំនងនៃអង្គការស៊ីប៉ាមានប្រសាសន៍ថា ចាប់ពីឆ្នាំ២០០០មកអង្គការស៊ីប៉ាបានបង្កើតកម្មវិធីបោះពុម្ពសៀវភៅជាភាសាខ្មែរសម្រាប់យុវជន។ដល់ឆ្នាំ២០១០ មាន៨០ចំណងជើងសៀវភៅស្ថិតនៅក្រុមសៀវភៅ "ខ្ញុំចង់ដឹង" "ប្រលោមលោកសម្រាប់យុវវ័យ" "ខ្ញុំចង់អាន" "រឿងដំបូងៗ" និង "សៀវភៅរូបភាព" របស់អង្គការស៊ីប៉ាត្រូវបោះពុម្ពផ្សាយ។ប្រធានបទរបស់សៀវភៅទាំងនោះមានទាក់ទងនឹងប្រវត្តិសាស្ត្រ ធម្មជាតិ បរិស្ថាន បច្ចេកទេស ព្រមទាំងសៀវភៅដែលទាក់ទឹងវីរជន ល្បីៗ-ល-។

ក្រៅពីការបោះពុម្ពសៀវភៅអង្គការស៊ីប៉ាបានបង្កើតនូវកម្មវិធីបណ្ណាល័យដែលជាអាទិភាពរបស់ខ្លួនដែរ។ ពីឆ្នាំ១៩៩៥ ដល់២០០៥ អង្គការស៊ីប៉ាបានពង្រីកបណ្តាញបណ្ណាល័យនៅក្នុងសាលាបឋមសិក្សាចំនួន១០០ នៅក្នុងខេត្ត-ក្រុងទាំង៨នៅព្រះរាជាណាចក្រកម្ពុជា។ពីឆ្នាំ២០០៥ដល់២០១០អង្គការបានពង្រឹងសមត្ថភាពវិស័យបណ្ណាល័យនៅក្នុងក្របខណ្ឌក្រសួងអប់រំ។បណ្ណាល័យចំនួន២១០ត្រូវបង្កើតឡើងនៅ២៤ខេត្ត-ក្រុង។ មានបណ្ណារក្សចំនួន១០០០នាក់ ត្រូវបានបណ្តុះបណ្តាលឡើងផងដែរដើម្បីគ្រប់គ្រងបណ្ណាល័យទាំងនោះ។



កម្មវិធីអង្គការស៊ីប៉ាមួយទៀតគឺកម្មវិធីបណ្ណាល័យចល័ត។ រថយន្តផ្ទុកណែនដោយសៀវភៅធ្វើដំណើរទៀងទាត់ទៅតំបន់ចំនួន៨០ នៅជុំវិញរាជធានីភ្នំពេញឱ្យប្រជាជនបានអានសៀវភៅ។គោលដៅរបស់បណ្ណាល័យចល័តមាន ភូមិ សង្កាត់ក្រីក្រ សាលាមត្តេយ្យ ឬមណ្ឌលកុមារកំព្រាជាដើម។

អ្នកស្រីស្តេផានី គ្រី ក៏បានវាយតម្លៃខ្ពស់ចំពោះកម្មវិធីបណ្ណាល័យចល័តដែលកំពុងដំណើរការល្អ និងមាននិន្នាការរីកចម្រើនជាលំដាប់។ អ្នកស្រីបានបន្តថា យើងកំពុងស្ថិតនៅក្នុងដំណើរការវិជ្ជមាននៃកម្មវិធីរបស់យើង។ យើងកំពុងស្ថិតនៅក្នុងដំណើរការនៃការវាយតម្លៃខ្លួនឯងឱ្យសកម្មភាពរបស់យើងល្អជាលំដាប់ និងបង្កើតសកម្មភាពថ្មីផ្សេងៗទៀត។ អ្នកស្រីបន្តទៀតថា អង្គការរបស់យើងនៅពឹងលើជំនួយពីដៃគូររបស់យើងនៅឡើយ។ ប៉ុន្តែគោលដៅចម្បងរបស់យើងគឺបង្កើតគ្រឹះស្ថានបោះពុម្ពដែលមានភាពស្វយត។ ដើម្បីសម្រេចគោលដៅនេះការផលិតសៀវភៅដែលមានគុណភាពខ្ពស់ និងមានតម្លៃថោក គឺជាការងារចាំបាច់ត្រូវតែអនុវត្តឱ្យបានដើម្បីមានសមត្ថភាពក្នុងការប្រកួតប្រជែងទីផ្សារ។

លោកហុក សុទ្ធិ នាយកអង្គការស៊ីប៉ា មានប្រសាសន៍ថា: "ការធ្វើឱ្យការបោះពុម្ពស៊ីប៉ាទៅស្ថាប័នស្វយតជាគោលបំណងរបស់យើងទៅថ្ងៃអនាគត។ ប៉ុន្តែត្រូវការពេលវេលាមិនតិចជាងប្រាំឆ្នាំឡើយ។" លោកហុក សុទ្ធិ មានប្រសាសន៍បន្តថា ដើម្បីឱ្យគ្រឹះស្ថាននេះក្លាយជាស្វយតយើងត្រូវបង្ហាញថាផលិតផលរបស់យើងមានទីផ្សារដើម្បីស្វែងរកចំណូលផ្គត់ផ្គង់ស្ថាប័ន។ យើងកំពុងសិក្សាអំពីរឿងនេះ។ ទីពីរ យើងត្រូវធានាថាក្រុមការងាររបស់យើងមានសមត្ថភាពគ្រប់គ្រាន់ដើម្បីផលិតផល។

លោកហុក សុទ្ធិ បន្តថា ក្រៅពីនេះយើងនឹងបន្តអភិវឌ្ឍបណ្ណាល័យចល័ត បណ្ណាល័យក្រៅសាលាដូចជានៅមន្ទីរពេទ្យ និងពន្ធធនាគារជាដើម។តាមប្រសាសន៍បន្តរបស់ ស្តេផានី គ្រី បានឱ្យដឹងទៀតថា ទន្ទឹមនឹងការជួយខាងវិស័យអំណាននៅកម្ពុជាអង្គការស៊ីប៉ាបានបណ្តុះបណ្តាលដល់បុគ្គលិកពីបែបបទការងារតាមវិជ្ជាជីវៈ។ វគ្គសិក្សាបណ្តុះបណ្តាលជាច្រើនត្រូវរៀបចំដើម្បីបង្កើនសមត្ថភាពទាក់ទងនឹងជំនាញសៀវភៅដូចជា អ្នកបោះពុម្ពផ្សាយ អ្នកនិពន្ធ អ្នកគំនូរ អ្នករចនាទំព័រ និងអ្នកចែកផ្សាយ។

# ព័ត៌មានទូទៅ



Photo : S. Philong

**ខាន់ ភិរម្យ**

## ព្រះសហគមន៍ចូលរួមកាន់ទុក្ខដល់ជនរង គ្រោះដោយសារឧបទ្ទវហេតុនៅកោះពេជ្រ

ព្រះសហគមន៍កាតូលិកនៅកម្ពុជា បានចូលរួមនៅក្នុងពិធីថ្វាយអភិបូជា ដល់ជនរងគ្រោះក្នុង ឧប្បត្តិហេតុនៅស្ពានកោះពេជ្រ ដែលបានសម្លាប់ជីវិតមនុស្ស ៣៥១នាក់ និងធ្វើឱ្យរបួសចំនួន ៣៩៥នាក់ ។

ពិធីថ្វាយអភិបូជាត្រូវបានប្រារព្ធឡើងនៅព្រះសហគមន៍ផ្សារតូចស្របពេលដែលរាជរដ្ឋាភិបាលកម្ពុជា ប្រកាសយកថ្ងៃទី២៥ ខែវិច្ឆិកា គឺជាថ្ងៃកាន់ទុក្ខដល់ជនរងគ្រោះទាំងអស់ ដែលបាត់បង់ជីវិតនៅក្នុង**ឧបទ្ទវហេតុ** កាលថ្ងៃទី២២ វិច្ឆិកា ជាថ្ងៃចុងក្រោយនៃព្រះរាជពិធីបុណ្យអុំទូក អកអំបុក សំពះព្រះខែ និងបណ្តែតប្រទីប ។

ពិធីនេះមានការចូលរួមពីលោកសុខកុមារអូលីវីយេ ជ្មីតអីស្លែរ អភិបាលនៃព្រះសហគមន៍ភូមិភាគភ្នំពេញ និង លោកគីកេ ហ្វីការេដូ អភិបាលនៃព្រះសហគមន៍ភូមិភាគបាត់ដំបង ។ លោកសុខកុមារ បានមានប្រសាសន៍ថា នេះគឺជាថ្ងៃដែលព្រះសហគមន៍កាតូលិកចូលរួមមរណទុក្ខ និងអធិដ្ឋានរួមគ្នា ដើម្បីចែករំលែកនូវសេចក្តីទុក្ខសោកដល់បងប្អូនដែលទទួលមរណភាព និងផ្តល់សេចក្តីសង្ឃឹមដល់បងប្អូនសាច់ញាតិជនរងគ្រោះ និងអ្នករងរបួសទាំងអស់ ។

លោកអភិបាលគីកេ នៃភូមិភាគបាត់ដំបង បានមានប្រសាសន៍ថា ព្រះសហគមន៍ភូមិភាគបាត់ដំបង មានក្តីរន្ធត់យ៉ាងខ្លាំងដែលបានឮឧប្បត្តិហេតុនេះ ហើយបានជួបជុំគ្នាអធិដ្ឋានគោរពវិញ្ញាណក្ខន្ធ និងលើកទឹកចិត្តដល់អ្នករបួស និងសាច់ញាតិជនរងគ្រោះតាំងតែពីថ្ងៃទី២៣ មកម្ល៉េះ ។

នៅក្នុងពិធីនោះ គេបានប្រកាសថា នៅក្នុងចំណោមជនរងគ្រោះទាំងអស់ ក៏មានគ្រីស្តបរិស័ទកាតូលិកមួយរូបផងដែរបានបាត់បង់ជីវិត ។

ជុំវិញ**ឧបទ្ទវហេតុ**នេះ ប្រមុខរដ្ឋាភិបាលកម្ពុជា បានអះអាងថា នេះគឺជាមហាសោកនាសកម្មនៅក្នុងប្រវត្តិនៃប្រទេសកម្ពុជា ជាពិសេសចាប់តាំងពីសម័យប្រល័យពូជសាសន៍ប៉ុលពតបានបញ្ចប់ទៅ ។

សម្តេចហ៊ុន សែន ប្រមុខរដ្ឋាភិបាលកម្ពុជា បានចេញនូវសេចក្តីថ្លែងការណ៍ភ្លាមៗ ហើយបានបញ្ជាឱ្យស៊ើបអង្កេត ហេតុការណ៍ និងដោះស្រាយស្ថានការណ៍ភ្លាមៗ ។ ជាលទ្ធផលកាលពីថ្ងៃទី២៩ វិច្ឆិកា កន្លងទៅនេះតាមរយៈគណៈកម្មការដោះស្រាយឧប្បត្តិហេតុលើស្ពានពេជ្របានឱ្យដឹងថា មូលហេតុចំបងនៃគ្រោះមហន្តរាយនេះ គឺបណ្តាលមកពីការផ្អើលឆោឡោជាន់គ្នា ដែលនាំឱ្យថប់ដង្ហើម និងរបួសមិនមែនកើតមានឡើងដោយសារការឆក់ខ្សែភ្លើង ឬក៏អំពើភេរវកម្មដែលមានការគ្រោងទុកនោះទេ ។

បន្ទាប់ពី**ឧបទ្ទវហេត**នេះ មូលនិធិមួយចំនួនបានត្រូវគេប្រកាសឡើងនៅក្នុងគោលបំណងប្រមូលមូលនិធិទៅជួយដល់ជនរងគ្រោះ ។ ហើយជាលទ្ធផលសម្តេចហ៊ុន សែន បានប្រកាសថា សពមួយទទួលថវិកាមិនតិចជាង ១២០០០ដុល្លារ ក្នុងនោះ៤០០០ដុល្លារ ត្រូវប្រគល់ដល់ដៃគ្រួសារជនរងគ្រោះរួចរាល់នៅសល់៩០០០ដុល្លារទៀតនឹងត្រូវប្រគល់ជាបន្តបន្ទាប់ ។ អ្នករងរបួស នឹងទទួលបាននូវការព្យាបាលដោយឥតគិតថ្លៃ ។

## កូរ៉េខាងជើងដាក់ពង្រាយកាំជ្រួចក្រោយបាញ់កាំភ្លើងធំចូលទឹកដីកូរ៉េខាងត្បូង

កាំជ្រួចពិឃាតដែលអាចបាញ់ចម្ងាយប្រមាណ ៩៥គីឡូម៉ែត្រ ជាច្រើនដើមត្រូវកូរ៉េខាងជើងយកមកដាក់ពង្រាយតាមព្រំដែនជាមួយនិងកូរ៉េខាងត្បូង ជាពិសេសតំបន់មានភាពតានតឹងនៅសមុទ្រលឿង ។

ទីភ្នាក់ងារព័ត៌មាន យ៉ុនហាប់ បានឱ្យដឹងថា កាំជ្រួចនេះប្រហែលជាកូរ៉េខាងជើងយកមកដាក់តម្រង់ទៅរកយន្តហោះកូរ៉េខាងត្បូងនៅជិតនឹងព្រំដែនក្នុងសមយុទ្ធធ្វើឡើងដោយកងទ័ពកូរ៉េខាងត្បូង និងសហរដ្ឋអាម៉េរិកក្រោយពេលកូរ៉េខាងជើងបានបាញ់កាំភ្លើងធំចូលទៅក្នុងទឹកដីកូរ៉េខាងត្បូងបណ្តាលឱ្យបាត់បង់ជីវិត ៤នាក់ និងរបួសចំនួន ១៨នាក់ ។

ការបាញ់ប្រហាររបស់កូរ៉េខាងជើងក្រោមលេសថា កូរ៉េខាងត្បូងបានបាញ់រំលោភចូលដែនទឹករបស់ខ្លួនបណ្តាលឱ្យរដ្ឋាភិបាល កូរ៉េខាងត្បូង និងអាមេរិក រៀបចំសមយុទ្ធ ជាបន្ទាន់មួយមានរយៈពេល ៤ថ្ងៃ កម្លាំងកងទ័ពប្រមាណជា ៥៥០០នាក់ នាវាពិឃាតនិង នាវាផ្ទុកយន្តហោះ ទម្ងន់ ៩៧.០០០តោន ដែលមាន យន្តហោះចំនួន ៧៥គ្រឿង ។



Photo : DR

## អាជ្ញាធរភូមាដោះលែង លោកស្រី អង់សាន ស៊ូជី

លោកស្រីអង់សាន សូជី មេដឹកនាំគាំទ្រលទ្ធិប្រជាធិបតេយ្យ នៅក្នុងប្រទេសភូមា ត្រូវអាជ្ញាធរយោធាក្នុងប្រទេសសម្រេចដោះលែងនៅក្នុងខែវិច្ឆិកានេះ។

ស្ត្រីដែលជាម្ចាស់ពានរង្វាន់ណូបែលសន្តិភាពពិភពលោកវ័យ ៦៥ឆ្នាំ និងជាមេដឹកនាំគាំទ្រលទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេស ត្រូវអាជ្ញាធរយោធាក្នុងប្រទេសនេះសម្រេចដោះលែងក្រោយពេលដែលលោកស្រីត្រូវចាប់ខ្លួន ហើយឃុំនាក្នុងផ្ទះអស់រយៈពេល៧ឆ្នាំ។

ក្រោយពីការដោះលែង លោកស្រីបានជួបជាមួយនឹងកូនប្រុសរបស់លោកស្រី និងបណ្តាអ្នកការទូត ព្រមទាំងអង្គការសហប្រជាជាតិជាបន្តបន្ទាប់។ នៅក្នុងជំនួបជាមួយនឹងប្រមុខការទូតនានា លោកស្រីបានអះអាងថា លោកស្រីនៅតែបន្តផែនការដើម្បីនាំយកនូវលទ្ធិប្រជាធិបតេយ្យទៅក្នុងប្រទេសភូមាជាបន្តទៅទៀត។

## បទសម្ភាសន៍

# អ្នកជំនាញ : ម្ហូបជាមត្តទេសក៏ និងជាសម្បត្តិវប្បធម៌របស់ខ្មែរ

**ខាន់ ភីរម្យ**

*តើលោកអ្នកដឹងទេថា ម្ហូបក្រៅពីមានតួនាទីជាអាហាររបស់មនុស្សហើយនោះ តើវាមានតម្លៃយ៉ាងណាចំពោះជាតិសាសន៍មួយ ? ដើម្បីឱ្យយល់ដឹងអំពីតម្លៃម្ហូបខ្មែរ អ្នកនាំសារ សូមណែនាំមិត្តអ្នកអានឱ្យជួបលោកស្រីឡុង ស្វីរុំ អ្នកនិពន្ធសៀវភៅ"នៅស្រុក ដែលមានផ្លែម្កាក់" ដែលជាម្ចាស់ពានរង្វាន់សៀវភៅមុខម្ហូបពិភពលោកឆ្នាំ២០០៩។*

**អ្នកនាំសារ : តើសៀវភៅ "នៅស្រុកដែលមានផ្លែម្កាក់" សរសេរអំពីអ្វី? ហេតុអ្វីបានសៀវភៅនេះជាប់ចំណាត់ថ្នាក់ជាសៀវភៅមុខម្ហូបពិភពលោក?**

**លោកស្រី ឡុង ស្វីរុំ :** នេះគឺជារឿងដែលមិននឹកស្មានដល់ តែវាគឺជាមោទនភាពមួយរបស់ខ្ញុំនិងកូនស្រីរបស់ខ្ញុំនៅក្នុងនាមជាជនជាតិខ្មែរដែលទទួលបានជ័យលាភីនេះ ។ សៀវភៅនេះ គឺជាស្នាដៃដែលនាងខ្ញុំសរសេរអំពីរឿងរ៉ាវផ្ទាល់ខ្លួនរបស់ខ្ញុំពាក់ព័ន្ធនឹងមុខម្ហូបខ្មែរមានរបៀបធ្វើម្ហូបខ្មែរចំនួន ១៣៩មុខ និងរូបថត ចំនួន១៥៨ផ្ទាំងក្នុងកម្រាស់សរុប២១៨ទំព័រ ជាភាសាបារាំង ។ សៀវភៅនេះគឺជាស្នាដៃទីមួយរបស់ខ្ញុំហើយបានត្រូវគេជ្រើសរើសទៅចូលរួមប្រកួតជាមួយនឹងសៀវភៅ



Photo : DR

**អ្នកស្រី ឡុងស្វីរុំ ថតរូបអនុស្សាវរីយ៍ជាមួយកូនស្រីរបស់គាត់នៅថ្ងៃទទួលជ័យលាភី**

៦០០០ មកពីជុំវិញពិភពលោក ។ ហើយនៅជុំចុងក្រោយសៀវភៅខ្ញុំជាប់ចំណាត់ថ្នាក់លេខមួយនៅក្នុងចំណោមសៀវភៅចំនួន៤ ដែលអ្នកសរសេរសៀវភៅមកពីបួនប្រទេសដែលរួមមានខ្ញុំតំណាងឱ្យប្រទេសខ្មែរក្រៅពីនោះមានប្រទេសអាយឡែនដាណឺម៉ាក និងសហរដ្ឋអាមេរិក ។

**អ្នកនាំសារ : ក្នុងនាមលោកស្រីជាម្ចាស់ជ័យលាភីសៀវភៅមុខម្ហូបពិភពលោក តើលោកស្រីយល់យ៉ាងណាចំពោះម្ហូបខ្មែរ? តើវាមានតម្លៃយ៉ាងណាដែរ ?**

**លោកស្រី ឡុង ស្វីរុំ :** ម្ហូបមិនមានតួនាទីត្រឹមតែជាអាហាររបស់មនុស្សតែមួយមុខទេ ។ ម្ហូបគឺជាអត្តសញ្ញាណ យើងក៏ជាមគ្គុទេស និងជាឯកអគ្គរដ្ឋទូតដ៏សំខាន់ផងដែរ ។ សៀវភៅនេះប្រាប់អ្នកអានត្រឹមតែ១៣៩មុខទេ ។ ប៉ុន្តែធាតុពិតខ្មែរយើងមានមុខម្ហូបរាប់សិបប្រភេទទៀត ។ ខ្មែរយើងមិនមែនមានត្រឹមតែប្រាសាទបុរាណទេដែលសម្រាប់ទាក់ទាញទេសចរណ៍ ។ ប៉ុន្តែម្ហូបក៏ជាប្រភពទាក់ទាញ និងជាសម្បត្តិវប្បធម៌មួយដ៏ថ្លៃថ្លៃផងផងហើយកូនខ្មែរត្រូវតែមានមោទនភាពនិងម្ហូបខ្មែរ ។

**អ្នកនាំសារ : មានសំណួរជាច្រើនអំពីភាពខុសគ្នារវាងម្ហូបខ្មែរ និងម្ហូបប្រទេសជិតខាងដែលមានវប្បធម៌ស្រដៀងខ្មែរយើងហើយក៏មានការបកស្រាយផ្សេងៗគ្នាជាច្រើនដែរ ចុះលោកស្រី តើលោកស្រីយល់យ៉ាងណា ?**

**លោកស្រី ឡុង ស្វីរុំ :** តាមបទពិសោធន៍នឹងការសិក្សាដោយផ្ទាល់ប្រភពដើមម្ហូបខ្មែរយើង ជាពិសេស គឺឆា និងស្ងោរ គឺមកពីចិន ។ រីឯគ្រឿងទេសវិញ គឺមានមកពីក្លិង្គ (ឥណ្ឌា) ប៉ុន្តែខ្មែរយើងចេះច្នៃឱ្យចេញលក្ខណៈពិសេសមួយរបស់ខ្លួន ។ លក្ខណៈពិសេស នៃការផ្សំគ្រឿងរបស់ខ្មែរយើងគឺផ្អែម និងប្រៃល្មម មិនលាយគ្រឿងហិលចូល ។ ប៉ុន្តែបើអ្នកទទួលទានចង់ពិសាររាងហិល គេនិយមថែមគ្រឿងខាងក្រៅជាពិសេស គឺម្ទេសស្រស់ ហើយមានរបៀបបុកគ្រឿងពិសេសឱ្យសម្លរមានពណ៌បៃតងស្រស់ និងពណ៌លឿងខ្ចី ។

### លោកស្រី ឡុង ស្វីរុំជានរណា ?

លោកស្រី ស្វីរុំ បានប្រសូតនៅក្នុងឆ្នាំ ១៩៤១ នៅក្នុងខេត្តក្រចេះនៅក្នុងគ្រួសារមួយដែលមានឪពុក គឺជាមន្ត្រីរាជការ និងម្ដាយជាអ្នកចំការមួយរូប។ លោកស្រីមានបងប្អូន៩នាក់។ លោកស្រីរៀបអាពាហ៍ពិពាហ៍នៅឆ្នាំ ១៩៦៨ ជាមួយអតីតនិស្សិតនៅស្រុកបារាំងមួយរូបឈ្មោះ ឡុង បុត្តា ដែលក្រោយមកត្រូវបានតែងតាំងជារដ្ឋមន្ត្រីក្រសួងអប់រំ កាលពីសម័យសង្គមរាស្ត្រនិយម ហើយមានបុត្រាបុត្រី ៣នាក់។

ក្រោយភៀសខ្លួនចេញពីប្រទេសកម្ពុជាដោយសារសង្គ្រាមលោកស្រី គឺជាសាស្ត្រាចារ្យជំនាញម្ហូបនៅសាលាបណ្តុះបណ្តាលវិជ្ជាជីវៈនៅក្នុងប្រទេសបារាំង។



Photo : DR

អ្នកស្រីឡុង ស្វីរុំ នឹងសាច់ញាតិលើកបង្ហាញវិញ្ញាបនបត្រ និងទង់ជាតិប្រទេសកម្ពុជាដែលបង្ហាញពីមោទនភាពជាតិពេលស្ត្រីជនជាតិខ្មែរម្នាក់បានទទួលពានរង្វាន់សៀវភៅម្ហូបអាហារក្នុងកម្រិតអន្តជាតិ។

**បទយកការណ៍**

# ស្ត្រីគឺជាឆ្អឹងខ្នងនៃការអភិវឌ្ឍ ប៉ុន្តែសមភា

**ខាន់ ភីរម្យ**

ការចូលរួមរបស់ស្ត្រីនៅក្នុងដំណើរការនៃការអភិវឌ្ឍប្រទេសជាតិកាន់តែមានការកើនឡើងគួរឱ្យកត់សម្គាល់ ប៉ុន្តែតាមសភាពជាក់ស្តែងគម្លាតនៃការចូលរួមរវាងស្ត្រី និងបុរសនៅកម្ពុជានៅមានគម្លាតធំនៅឡើយ ។ នេះបើតាមការអះអាងរបស់ស្ត្រីដែលកំពុងតែធ្វើការដើម្បីសមភាពយេនឌ័រនៅក្នុងប្រទេស ។

លោកស្រីមៀច សុធារី អគ្គលេខាធិការរងនៃសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ បានមានប្រសាសន៍ថា តាមគោលការណ៍ និងការកំណត់យុទ្ធសាស្ត្រដឹកនាំប្រទេសរបស់រាជរដ្ឋាភិបាលកម្ពុជាស្ត្រីមានតួនាទីជាឆ្អឹងខ្នងនៃការអភិវឌ្ឍទាំងប្រទេសជាតិ និងគ្រួសារ ។ ប៉ុន្តែបើនិយាយពីតួនាទីក្នុងការដឹកនាំ និងការធ្វើសេចក្តីសម្រេចចិត្តវិញនោះ ការចូលរួមរវាងស្ត្រី និងបុរសនៅតែមានគម្លាត ។

លោកស្រីបានបញ្ជាក់ថា "តាមវប្បធម៌ និងប្រវត្តិសាស្ត្រស្ត្រីច្រើនស្ថិតនៅក្នុងតួនាទីជាអ្នកប្រតិបត្តិច្រើនជាងការសម្រេចចិត្ត ។ ប៉ុន្តែបច្ចុប្បន្ននេះការចូលរួមរបស់ស្ត្រីក្នុងឋានៈជាអ្នកធ្វើសេចក្តីសម្រេចចិត្តនេះ គឺមានលក្ខណៈទំលំទូលាយ និងច្រើនជាងមុន" ។

តាមប្រសាសន៍របស់លោកស្រី មៀច សុធារី មកដល់ឆ្នាំ ២០១០ ដោយសារតែការលើកទឹកចិត្តរបស់រាជរដ្ឋាភិបាល និងមានការតស៊ូមតិផ្សេងៗរបស់បណ្តាអង្គការសង្គមស៊ីវិលនានា នៅប្រទេសកម្ពុជា ស្ត្រីមានឱកាស និងទទួលបានការចូលរួមច្រើនក្នុងជួរថ្នាក់ដឹកនាំ នឹងការធ្វើសេចក្តីសម្រេចចិត្តផ្សេងៗបានដែរ ។

លោកស្រី បានរៀបរាប់ថា នៅក្នុងចំណោមប្រជាពលរដ្ឋកម្ពុជាទាំងអស់ ស្ត្រី មានចំនួនជាង ៥០% ។ ប៉ុន្តែ នៅក្នុងជួរការងារដែលស្ថិតនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត ស្ត្រីនៅមានចំនួនតិច ។

យោងតាមជំរឿនឆ្នាំ២០០៨ ក្នុងចំណោមប្រជាពលរដ្ឋសរុប ១៣,៣លាននាក់ ស្ត្រីមានរហូតដល់ទៅ៥១,៥% ។ នៅក្នុងនោះ ស្ត្រីជាមេគ្រួសារមានចំនួនត្រឹមតែ ២៥,៦%តែប៉ុណ្ណោះ ។

ចំនួនស្ត្រីចេះអក្សរមានត្រឹមតែ ៧០,៨៦%ទេ ខណៈដែលបុរសមានរហូតដល់ទៅ ៨៥,០៨% ។

យោងទៅតាមស្ថិតិអំពីយេនឌ័រដែលរៀបរៀងដោយនាយកដ្ឋានផែនការ និងស្ថិតិនៃក្រសួងកិច្ចការនារី បានបង្ហាញឱ្យរឹតតែឃើញច្បាស់នូវគម្លាតរវាងនារី និងបុរសនៅក្នុងការចូលរួមការអភិវឌ្ឍប្រទេសជាតិ ។

ប្រភពដដែលនោះបានឱ្យដឹងថា ក្នុងឆ្នាំ ២០០៩ នេះ ក្នុងចំណោមគ្រូកម្រិតបឋមសិក្សាទាំងអស់ ចំនួនស្ត្រីដែលបានចូលរួមការងារនេះមានចំនួន ៤៤,៧៨% ។ កម្រិតអនុវិទ្យាល័យការចូលរួមរបស់ស្ត្រីបានធ្លាក់មកនៅត្រឹមតែ ៣៣,៧០% ។ ប៉ុន្តែវាបានកើនឡើងវិញនៅកម្រិតវិទ្យាល័យមកត្រឹម ៣៤,៦៣% ។

ប្រភពដដែលនោះបានឱ្យដឹងទៀតផងដែរថា សមាមាត្ររបស់ស្ត្រីក្នុងថ្នាក់ដឹកនាំខេត្ត-រាជធានីមានចំនួនតិចតួចនៅឡើយ ។ មកដល់ ឆ្នាំ២០១០ នេះ គឺគ្មានស្ត្រីណាម្នាក់ដែលទទួលបានការងារជាអភិបាលខេត្តនៅឡើយទេលើកលែងតែអភិ



### ឧបសគ្គរបស់ស្ត្រីនៅក្នុងការចូលរួមអភិវឌ្ឍន៍ជាតិ

លោកស្រីមៀច សុធារី អគ្គលេខាធិការរងសមាគមកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ បានមាន ប្រសាសន៍ ថា ឧបសគ្គចម្បងនៅ ក្នុងការជំរុញឱ្យមានការចូលរួមរបស់ស្ត្រីនៅក្នុងដំណើរការអភិវឌ្ឍ ប្រទេសជាតិនោះ គឺបរិបទ ប្រពៃណី និងជំនឿចិត្តផ្ទាល់ខ្លួនរបស់ស្ត្រី។

លោកស្រី បានបញ្ជាក់ឱ្យដឹងថា តាមបរិបទប្រពៃណី ច្រើនតែឱ្យតម្លៃស្ត្រីសម្រាប់ការទទួលខុសត្រូវនៅក្នុងគ្រួសារ។ ដូច្នេះវាលំបាកណាស់នៅក្នុងការជំរុញឱ្យស្ត្រីចេញមកធ្វើការនៅខាងក្រៅផ្ទះ ហើយម្យ៉ាងទៀត ស្ត្រីខ្លួនឯង ច្រើនខ្វះទំនុកចិត្តទៅលើសមត្ថភាពដែលខ្លួនឯងមាន។

លោកស្រីបានបន្តទៀតថា មកដល់ពេលនេះ ស្ត្រីភាគច្រើននៅតែយល់ថា ការធ្វើដំណើរនៅឆ្ងាយពីផ្ទះ គឺនឹងធ្វើឱ្យ ខ្លួនជួបការលំបាក និងខ្វះសុវត្ថិភាព។

# ពភេទនៅតែមានគម្លាតឆ្ងាយ



Photo : S. Philong

បាលរង។ នៅក្នុងជួរសមាជិកក្រុមប្រឹក្សារាជធានីខេត្ត នៅក្នុងចំណោមមន្ត្រីចំនួន ៣៧៤រូប ស្ត្រីមានចំនួនតែ ៣៧រូបទេ ហើយបើនិយាយអំពីសមាជិកក្រុមប្រឹក្សាក្រុង ស្រុកខណ្ឌ នៅក្នុងចំណោមមន្ត្រី ២៨៦១នាក់ មានស្ត្រីត្រឹមតែ ៣៦៣នាក់ប៉ុណ្ណោះ។

ប្រភពដដែលនោះបានឱ្យដឹងទៀតថា ភាគរយស្ត្រីដែលមានតួនាទីជាថ្នាក់ដឹកនាំនៅថ្នាក់ក្រោមជាតិនៅក្នុងឋានៈជាប្រធានមន្ទីរ មានចំនួនត្រឹមតែ ៧% ខណៈដែលអនុប្រធានមានចំនួន៩% ហើយប្រធានការិយកាល័យមានចំនួន១៤% និងអនុប្រធានការិយាល័យមានចំនួន១៨%។ ចំណែកស្ត្រីដែលមានតួនាទីនៅថ្នាក់ដឹកនាំលំដាប់ជាតិ ឬស្ត្រីដែលកំពុងតែកាន់តំណែងជាអគ្គនាយក មានចំនួនត្រឹមតែ៧% អគ្គនាយករង៩% ប្រធាននាយកដ្ឋានមានចំនួន១០% ហើយអនុប្រធាននាយកដ្ឋានវិញមានចំនួន១៥% ប្រធានការិយាល័យមានចំនួន ១៧% និងអនុប្រធានការិយាល័យមានចំនួន ២៣ % ។

ប្រភពដដែលនោះបានឱ្យដឹងទៀតថា ភាគរយស្ត្រីនៅក្នុងប្រព័ន្ធតុលាការ មានការកើនឡើងតិចតួចនៅក្នុងឆ្នាំ ២០១០។ ស្ត្រីមួយរូបបានត្រូវតែងតាំងជាអគ្គព្រះរាជអាជ្ញាក្នុងចំណោមអគ្គព្រះរាជអាជ្ញា ២រូប។ ប៉ុន្តែគ្មានស្ត្រីណា ម្នាក់កាន់ការងារជាអគ្គព្រះរាជអាជ្ញារងឡើយ។

ប្រភពដដែលបានឱ្យដឹងទៀតថា មកដល់ពេលនេះនៅក្នុងចំណោមចៅក្រមចំនួន ២០៨រូបស្ត្រីមានចំនួនត្រឹមតែ ២៩រូបប៉ុណ្ណោះ ខណៈដែលស្ត្រីបម្រើការងារជាក្រឡាបញ្ជីមានត្រឹមតែ ១៨%។

លោកស្រី មៀច សុធារី បានឱ្យដឹងថា នៅក្នុងចំណោមកិច្ចការលើគ្រប់វិស័យ វិស័យដែលពិនិត្យមើលឃើញថា មានស្ត្រីចូលរួមច្រើនជាងគេនោះគឺមានតែការងារកសិកម្មតែប៉ុណ្ណោះ ក្រៅពីនោះបុរសជាអ្នកកាន់កាប់ការងារភាគច្រើនទាំងអស់។

កញ្ញាអ៊ុន ឈាត្រា សមាជិកព្រះសហគមន៍ និងជាអ្នកទទួលខុសត្រូវក្នុងក្រុមគ្រួសារពន្លឺមិត្តភាពដែលជាក្រុមគ្រួសារមួយនៅក្នុងព្រះសហគមន៍កាតូលិកនៅកម្ពុជាដែលកំពុងតែធ្វើការជាមួយនិងក្រុមនារីរោងចក្រកាត់ដេរនៅទីក្រុងភ្នំពេញបានមានប្រសាសន៍ថា បើនិយាយពីសមភាពយ៉េនឌ័រកុំថាឡើយប្រទេសកម្ពុជា សូម្បីតែនៅប្រទេសរីកចម្រើនក៏នៅមិនទាន់មានដែរ គ្រាន់តែគេមានស្ថានភាពប្រសើរជាងប៉ុណ្ណោះ។

កញ្ញាបានបញ្ជាក់ថា បើទោះបីជាមានការងារធ្វើខាងក្រៅផ្ទះក៏ពិតមែន ប៉ុន្តែស្ត្រីត្រូវប្រឈមមុខនឹងកត្តាជាច្រើន។

តាមប្រសាសន៍របស់កញ្ញាអ៊ុន ឈាត្រា ការងារដែលស្ត្រីនៅជនបទ សព្វថ្ងៃនេះអាចស្វែងរកបានច្រើនជាងគេ គឺនៅក្នុងវិស័យឧស្សាហកម្មកាត់ដេរ។ ប៉ុន្តែប្រសិនបើពួកគេបម្រើការងារនៅក្នុងវិស័យនេះយូរទៅ គាត់អាចប្រឈមមុខនឹងបញ្ហាសុខភាពបាត់បង់ទំនាក់ទំនង និងភាពជិតស្និទ្ធនៅក្នុងគ្រួសារ ភ្លេចតួនាទីរបស់ខ្លួន ដែលនេះនឹងធ្វើឱ្យគាត់ជួបការលំបាកក្នុងការធ្វើសមាហរណកម្មទៅក្នុងគ្រួសារ ប្រសិនបើគាត់បាត់បង់ការងារធ្វើ។

កញ្ញាបានបញ្ជាក់ថា : "ខ្ញុំគិតថា ធ្វើការនៅរោងចក្រពី ១០ឆ្នាំទៅ គាត់នឹងមានបញ្ហាសុខភាព ហើយមានទម្លាប់ធ្វើការដូចជារូប៉ូ (មនុស្សយន្ត) អ៊ីចឹង"។

កញ្ញាបានបន្តទៀតថា ដោយព្រួយបារម្ភចំពោះកត្តាទាំងនេះ យើងព្យាយាមជួយគាត់ឱ្យយល់អំពីតួនាទី និង តម្លៃនៅក្នុងទំនាក់ទំនងគ្រួសារ និងសង្គម ដើម្បីអាចឱ្យគាត់អាចធ្វើសមាហរណកម្មខ្លួនឯងបានទៅក្នុងគ្រួសារនៅពេលប្រសិនបើគាត់បាត់បង់ការងារធ្វើ ឬជួបប្រទះបញ្ហាណាមួយ។

កញ្ញា ជា រតនា កម្មការិនី នៅរោងចក្រ៦ជាន់ មកពីស្រុកបារាយ ខេត្តកំពង់ធំ បានឱ្យដឹងថា : "ខ្ញុំចង់ធ្វើគ្រូបង្រៀន តែឪពុកម្តាយខ្ញុំគាត់ក្រ។ គាត់ឱ្យខ្ញុំឈប់រៀន និងជួយរកប្រាក់ផ្គត់ផ្គង់ប្អូនប្រុសខ្ញុំ"។

រតនាបានឱ្យដឹងថា នាងមិនចង់ធ្វើកម្មករកាត់ដេរទេ ជាពិសេសនៅពេលដែលនាងបានចូលរៀនថ្នាក់ទី៧ ទៅហើយនោះ។ ប៉ុន្តែដើម្បីគ្រួសារ នាងត្រូវតែឈប់រៀន។

លោកស្រីមៀវ សុធារី ឱ្យដឹងថា ភាពក្រីក្រជាបញ្ហាចម្បងបំផុតធ្វើឱ្យស្ត្រីស្ថិតនៅក្នុងសភាពងាយរងគ្រោះ។ លោកស្រីបានបញ្ជាក់ថា : "បើសិនគ្រួសារមួយមានបញ្ហាលំបាកក្នុងជីវភាពគ្រួ-សារច្បាស់ជាឱ្យកូនស្រីឈប់រៀនមុនកូនប្រុស"។

## ការចូលរួមរបស់ស្ត្រីនៅក្នុងវិស័យនយោបាយ

ក្រសួងកិច្ចការនារីបានឱ្យដឹងថា មកដល់ពេលបច្ចុប្បន្ននេះ ស្ត្រីដែលកំពុងតែស្ថិតនៅក្នុងវិស័យនយោបាយ មានការកើនឡើង។ ប៉ុន្តែគេអះអាងថា វានៅមានកម្រិតទាប បើប្រៀបធៀបនឹងមធ្យមភាគជាអន្តរជាតិនៃប្រទេសដែលបានសម្រេចនូវភាពស្មើគ្នានៅក្នុងការបោះឆ្នោត។

ប្រភពដដែលនោះបានឱ្យដឹងថា នៅក្នុងការបោះឆ្នោតសភាកាលពីឆ្នាំ ២០០៨នោះ ស្ត្រីដែលជាសមាជិកសភាមាន ចំនួនសរុបទាំងអស់២២% ខណៈដែលនៅក្នុងស្ថាប័នព្រឹទ្ធសភាវិញនោះគឺមានចំនួន ១៤,៨% នៃសមាជិកសភាទាំងអស់ ។

ប្រភពដដែលនោះបានឱ្យដឹងថា នៅក្នុងជួររដ្ឋាភិបាលវិញ ស្ត្រីដែលត្រូវបានតែងតាំងជាឧបនាយករដ្ឋមន្ត្រីមានមួយ រូប និងថ្នាក់រដ្ឋមន្ត្រី មានចំនួន ២រូប។

យោងទៅតាមផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ និងគោលដៅអភិវឌ្ឍសហសវត្សរ រដ្ឋាភិបាលកម្ពុជាកំពុងតែ ជំរុញការចូលរួមរបស់ស្ត្រីឱ្យកាន់តែច្រើននៅក្នុងគ្រប់ផ្នែករួមទាំងផ្នែកនយោបាយស្របតាមពាក្យស្លោកមួយឃ្លារថា ស្ត្រីគឺជាឆ្អឹងខ្នងនៃការអភិវឌ្ឍន៍។

# ការីតាសកម្ពុជាជួបសន្ទនាជាមួយអង្គការដៃគូ

**ជាត សំភី**


Photo : P. Samphy

ការីតាសកម្ពុជា ជាមួយ និងអង្គការដៃគូរបស់ខ្លួនចំនួន ១២បានជួបប្រជុំដើម្បីគិតគូរអំពីរបៀបសហការគ្នាឱ្យបានកាន់ តែប្រសើរដែលរៀបចំធ្វើឡើងរយៈពេល បីថ្ងៃ ២៤-២៦ វិច្ឆិកា មុននេះ នៅការិយាល័យការីតាសរាជធានីភ្នំពេញ។

លោកអភិបាលគីកេ ហ្វីការេដូ ដែលជាប្រធានការីតាសកម្ពុជា មានប្រសាសន៏ថា យើងទាំងអស់គ្នាមកទីនេះ គឺដើម្បីគិតគូរអំពីរបៀបដែលយើងសហការគ្នាក្នុងគោលបំណងធ្វើឱ្យការងាររបស់អង្គការជាដៃគូរបស់យើងមានភាពងាយស្រួល និងការងាររបស់អង្គការការីតាសកម្ពុជាក៏ងាយស្រួលដែរ ពីព្រោះយើងមានបំណងអាទិភាពរួម។

លោក អភិបាលគីកេ ហ្វីការេដូ មានប្រសាសន៏ថា : "បំណងទីមួយ គឺបំពេញសេចក្តីត្រូវការរបស់អ្នកក្រីក្រ។ យើងជួយអ្នកក្រីក្រឱ្យគេមានសមត្ថភាពខ្លួនគេ។ ទីពីរ អង្គការដៃគូជួយគាំទ្រយើងឱ្យមានទីពឹងខ្លួនឯងឱ្យមានបុគ្គលិកដែលមានកម្រិតអន្តរជាតិ ចេះយល់អំពីការអភិវឌ្ឍជនបទ និងចេះជួយអ្នកក្រីក្រ។ ទីបី គេជួយយើងឱ្យមានបណ្តាញសហការគ្នាជាមួយអង្គការច្រើនឱ្យយើងចេះជួយគ្នាទៅវិញទៅមក ឱ្យចេះសហការជាមួយរដ្ឋាភិបាល និងជាមួយ អង្គការផ្សេងៗ។

កម្មវិធីប្រជុំនេះមានអ្នកចូលរួម ៤០នាក់ មានបុគ្គលិកការីតាស និងប្រធានកម្មវិធីការីតាសតាមខេត្ត ព្រមទាំងអ្នកតំណាងមកពីអង្គការការីតាសបារាំង អង្គការការីតាសអាម៉េរិក អង្គការការីតាសអូស្ត្រាលី អង្គការការីតាសស៊ុយអែត អង្គការការីតាសកូរ៉េ អង្គការការីតាសអាឡឺម៉ង់ និងអង្គការការីតាសឆេកូ។

កញ្ញាសារី ភីរម្យ ប្រធានកម្មវិធីអភិវឌ្ឍន៏យុវ-ជននៃអង្គការការីតាសនៅខេត្តកណ្តាលបានមានប្រសាសន៏ថា : "ខ្ញុំគិតថា កិច្ចប្រជុំនេះ គឺមានលក្ខណៈល្អប្រសើរ"។ កញ្ញាសារី ភីរម្យ បន្តថា យើងយល់ដឹងច្រើនអំពីទំនាក់ទំនង និងការពង្រឹងកិច្ចសហប្រតិបត្តិការរវាងការីតាសជាមួយនឹងម្ចាស់ជំនួយ។ ម្យ៉ាងទៀត អង្គការដៃគូនឹងបានយល់ដឹងច្រើនពីការរីកចម្រើនរបស់អង្គការការីតាសកម្ពុជា។

អ្នកនាងដូមីនីក ឆយ តំណាងអង្គការដៃគូនៅកូរ៉េ មានប្រសាសន៏ដែរថា : "ខ្ញុំត្រូវតែនិយាយថា នេះគឺជាការប្រជុំដ៏អស្ចារ្យ ក្នុងការចែករំលែកព័តិមាន និងយោបល់ ដោយសារយើងមានគោលដៅរួម ដើម្បីជួយដល់ប្រជាជនដែលត្រូវការជំនួយនៅក្នុងប្រទេសកម្ពុជា"។ អ្នកនាង មានប្រសាសន៏បន្តទៀតថា យើងចង់និយាយថា យើងមិនមែនគាំទ្រការីតាសកម្ពុជាតែម្ខាង យើងក៏ទទួលបាននូវការគាំទ្រពីអង្គការការីតាសកម្ពុជា និងអង្គការដៃគូនានាផងដែរ។ ពោល គឺយើងរៀនសូត្រពីគ្នាទៅវិញទៅមក និងគាំទ្រគ្នាទៅវិញទៅមក។

ចំណែកអ្នកនាងអេម៉ានូអែល តំណាងនៃអង្គការការីតាសបារាំងបានមានប្រសាសន៏ផងដែរថា : "ខ្ញុំមានការសប្បាយរីករាយណាស់ដែលបានចូលរួមនៅក្នុងកិច្ចប្រជុំនេះ។ វាជាឱកាសល្អសម្រាប់ខ្ញុំបានជួបនឹងសហការីដែលស្ថិតនៅក្នុងបណ្តាញអង្គការការីតាសដែលធ្វើការជាមួយអង្គការការីតាសកម្ពុជា។ នេះគឺជា កិច្ចប្រជុំដ៏ល្អអាចចែករំលែកនូវព័តិមាន និងបទពិសោធន៏ការងារឱ្យគ្នាទៅវិញទៅមក។ អ្នកនាង អេម៉ានូ អែល បញ្ជាក់ថា : "អង្គការការីតាសបារាំង និងការីតាសកម្ពុជាមានទំនាក់ទំនងគ្នាដាច់ដោយឡែកដោយមានប្រវត្តិជាមួយគ្នាជាច្រើនឆ្នាំមកហើយ"។

# លំនៅដ្ឋាន ១៣៥ខ្នង ត្រូវបានសាងសង់ថ្មី និងធ្វើការជួសជុល

នៅខេត្តចំនួនបី ក្នុងនោះ មានខេត្តសៀមរាប កំពង់ចាម និងកំពង់ធំ ដែលបានទទួលរងដោយខ្យល់ព្យុះកេតសេណា និងបង់ខាតនូវទ្រព្យសម្បត្តិព្រមទាំងផ្ទះសម្បែង កាលពីឆ្នាំ២០០៩ទៅមិញមានផ្ទះ ៥ខ្នង បានជួសជុលរួចនៅ ខេត្តសៀមរាប និងពីរខ្នងទៀត គឺខេត្តកំពង់ចាម និងកំពង់ធំ កំពុង ស្ថិតនៅក្នុងការរៀបចំ។

លោកសុខ សាខន មន្ត្រីទទួលបន្ទុកផ្នែកគ្រប់គ្រងគ្រោះមហន្តរាយនៃអង្គការការីតាសកម្ពុជាបានឱ្យដឹងថា មានការសាងសង និងជួសជុលគេហដ្ឋានជូនប្រជាពលរដ្ឋចំនួន ១៣៥គ្រួសារ ក្នុងនោះមាន៩៥ខ្នង ត្រូវសាងសង់ថ្មី និងផ្ទះ៩០ខ្នង ត្រូវបានធ្វើការជួសជុល។ ជាមួយគ្នានេះ អង្គការការីតាស កម្ពុជាក៏កំពុងរៀបចំវគ្គបណ្តុះបណ្តាលស្តីអំពី ការគ្រប់គ្រងគ្រោះមហន្តរាយ និងការ បម្រែបម្រួល អាកាសធាតុដែលមានរយៈពេលពីរថ្ងៃនៅ ខេត្តកំពង់ចាម ស្រុកពញាក្រែក គឺនៅថ្ងៃទី៣-៤ វិច្ឆិកា ឆ្នាំ២០១០។

លោកបានពន្យល់ពីគោលបំណងនៃការរៀបចំនូវវគ្គបណ្តុះបណ្តាលដល់អ្នកភូមិថា ជាការសំខាន់ដែលប្រជាពលរដ្ឋគួរមានការស្វែងយល់ អំពីភាពផ្សាំ និងកាត់បន្ថយនូវបម្រែបម្រួលអាកាសធាតុដែលមានការទាក់ទងទៅ និងទង្វើរបស់មនុស្សព្រមទាំងកត្តាផ្សេងៗទៀតដូចជា ការដាំដើមឈើមិនបោះសម្រាមពាសវាលពាសកាលដែលជាការបំពុលបរិស្ថាន។ ទាំងនេះជំរុញឱ្យបាននូវយុទ្ធសាស្ត្រក្នុងការកាត់បន្ថយគ្រោះមហន្តរាយ។ រយៈពេលកន្លងមកអង្គការការីតាសក៏បានរៀបចំវគ្គបណ្តុះបណ្តាលស្តីអំពីការបង្កាគ្រោះមហន្តរាយ និងផលបម្រែបម្រួលអាកាសនៅខេត្តណ្តាលកាលពីខែកក្កដាឆ្នាំនេះ។

## ការីតាសបញ្ចុះបឋមសិលាអគារថ្មី ផ្នែកជំងឺសុខភាពផ្លូវចិត្តកុមារ


Photo : DR

អគារសម្រាប់មើលថែអ្នកជំងឺផ្នែកសុខភាពផ្លូវចិត្តកុមារនេះមានទំហំ ១១៥០ម៉ែត្រការ៉េ និងមានកម្ពស់ ២ជាន់ កំពុងត្រូវបានសាងសង់ដោយមានការចូលរួមមូលនិធិចំនួន ៣០ ម៉ឺនដុល្លារ ពីអង្គការការីតាសកម្ពុជា ប្រទេស ឥណ្ឌា ប្រទេសប្រេស៊ីស និងអាហ្វ្រិកខាងត្បូង។

កម្មវិធីបញ្ចុះបឋមសិលា ប្រព្រឹត្តិទៅក្រោមអធិបតីភាពរបស់លោកអភិបាលសុខកុមារ អូលីវីយេ ស្មឺតអឺស្ទែរ អភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ ឯកឧត្តមម៉ម ប៊ុនហេង មន្ត្រីក្រសួងសុខាភិបាល និងឯកឧត្តម សាដេវ៉ា ឯកអគ្គរដ្ឋទូតឥណ្ឌាប្រចាំនៅប្រទេសកម្ពុជា លោកគីម រតនា នាយកប្រតិបត្តិនៃអង្គការការីតាសកម្ពុជានិងភ្ញៀវជាតិ និងអន្តរជាតិជាច្រើនរូប។

លោកអភិបាលមានប្រសាសន៍ថា ការលើកកម្ពស់សុខភាពផ្លូវចិត្តកុមារ និងយុវវ័យតាមរយៈមណ្ឌលសុខភាពផ្លូវចិត្តកុមារ និងយុវវ័យ ជាកម្មវិធីថ្នាក់ជាតិដោយកិច្ចសហប្រតិបត្តិការជាមួយក្រសួងសុខាភិបាល។ លោកបន្តថា អង្គការការីតាសកម្ពុជាមានគោលបំណងអភិវឌ្ឍនូវសេវាកម្មគំរូមួយ ដើម្បីជួយដល់កុមារមានតម្រូវការពិសេស គឺរកឱ្យឃើញពីគម្រោងដែលអាចវាស់វែងបាន និងអាចឆ្លើយតបបានត្រូវបានផ្សព្វផ្សាយដើម្បីឱ្យមានការចាប់អារម្មណ៍ពីបណ្ដាលប្រទេសដែលកំពុងអភិវឌ្ឍក្នុងការប្រយុទ្ធប្រឆាំងភាពក្រីក្រ និងភាពអត់ឃ្លាន។

នៅក្នុងសេចក្ដីនេះឯកឧត្តមម៉ម ប៊ុនហេងមានប្រសាសន៍ថា ការពង្រឹងសុខភាពផ្លូវចិត្តពិតជាសំខាន់សម្រាប់សុខាមាលភាពប្រជាជនដែលទាមទារឱ្យមន្ត្រីសុខាភិបាលទាំងអស់បន្តអនុវត្តកាយវិការល្អ និងគោរពក្រមសីលធម៌វិជ្ជាជីវៈជាពេទ្យឱ្យកាន់តែប្រសើរជាការផ្ដល់ទំនុកចិត្ត និងភាពកក់ក្ដៅដល់បងប្អូន។

សព្វថ្ងៃមជ្ឈមណ្ឌលសុខភាពផ្លូវចិត្តកុមារ មានបុគ្គលិកបម្រើការងារសរុបចំនួន១៥រូបក្នុងនោះមានមកពីអង្គការការីតាសចំនួន៩រូប និងក្នុងរយៈពេល ៩ខែកន្លងទៅបានទទួលអ្នកជម៉ឺសរុបចំនួន៤២៩៨នាក់ ចំណូលថ្មី២៩២នាក់ គិតជាមធ្យម ១ខែទទួលអ្នកជំងឺបាន៤៥០នាក់ មកពីបណ្ដាខេត្ត១៨ផ្សេងៗគ្នា។

លោកគីម រតនាបន្តថា អគារថ្មីនេះមិនត្រឹមតែផ្ដល់ជាកន្លែងព្យាបាលនឹងជាថ្នាលសម្រាប់បណ្ដុះបណ្ដាលនៃភាពប្រាកដជាក់ និងទំនួលខុសត្រូវរបស់គ្រូពេទ្យ និងបុគ្គលិកការងារទាំងអស់លើសេវាកម្ម និងកម្រិតព្យាបាល។ ម្យ៉ាងអគារថ្មីនេះផ្ដល់ឱកាសឱ្យសិស្សានុសិស្សដែលទើបនឹងបញ្ចប់ការសិក្សាជំនាញ ចិត្តសាស្ត្រឬជំនាញពាក់ព័ន្ធមកធ្វើការស្វែងយល់។

**អ៊ឹម សុខន**

## យើងជាគ្រីស្តបរិស័ទក្នុងសង្គមរបស់យើង!


Photo : Nith

"យើងជាគ្រីស្តបរិស័ទក្នុងសង្គមរបស់យើង"ជាប្រធានបទសិក្ខាសាលារៀបចំដោយការិយាល័យយុវជន និងកុមារភូមិភាគភ្នំពេញនាថ្ងៃទី២៧-២៨ វិច្ឆិកា ឆ្នាំ២០១០ នៅមណ្ឌលសកម្មភាពព្រះសហគមន៍កំពត ។

គោលបំណងនៃសិក្ខាសាលានេះធ្វើឡើងជាការស្វែងយល់ដឹងផ្នែកសង្គមសម្រាប់យុវជន ។ យុវជនចូលរួមចាប់ពីអាយុ១៦ឆ្នាំឡើងទៅសរុប៥១នាក់ ។

បើតាមសំដីរបស់លោកស៊ាន់ សារឿនជាអ្នកសម្របសម្រួលនៃអង្គសិក្ខាសាលានេះបាននិយាយថា លោកពិតជាសប្បាយចិត្តចំពោះការមើលឃើញនូវចំណាប់អារម្មណ៍យុវជនលើប្រធានបទតាមរយៈមតិយោបល់របស់យុវជនដែលបានឆ្លុះបញ្ចាំងពីជីវិតពិតទាំងក្នុងគ្រួសារ សហគមន៍ និងសង្គម ។

យុវនារីសែម រ័ត្ន មកពីព្រះសហគមន៍ជុំគីរីបាននិយាយថា យុវជនចេះចែករំលែកនូវបទពិសោធន៍ពីគ្នាទៅវិញទៅមកជាសញ្ញាបញ្ជាក់ថាយើងរស់នៅក្នុងសង្គមតែមួយ និងគ្រួសារតែមួយ ។

**នូ អច្ឆរិចិត្រ្តាស**

## ការប្រមូលហត្ថលេខាស្ដីពីការលុបបំបាត់ការប្រើគ្រាប់បែកចង្កោម

តាមការបង្ហាញពីគោលបំណងនៃការរៀបចំឱ្យមាននូវក្បួនដង្ហែទូក កាលពីថ្ងៃទី៣១ តុលានេះ កញ្ញាសុង កុសល ជាអគ្គរាជទូតជនពិការប្រទេសកម្ពុជានៃអង្គការ ជេស្វីត ប្រចាំព្រះរាជាណាចក្រកម្ពុជាបាននិយាយថា: "នេះជាការប្រមូលហត្ថលេខាគាំទ្រមិនឱ្យមានការប្រើគ្រាប់បែកចង្កោមនៅប្រទេសកម្ពុជា" ។

កម្មវិធីនេះប្រព្រឹត្តិទៅដោយមានជនរងគ្រោះដោយសារគ្រាប់បែកចង្កោម និងមីនតាមបណ្ដាខេត្តដូចជា ក្រចេះ កំពង់ចាម បាត់ដំបង សរុប៤៥នាក់និងអង្គការក្រៅរដ្ឋាភិបាលមួយចំនួនទៀតស្មើនឹង១២០នាក់ ។ កម្មវិធីដំណើរការតាមបណ្ដោយដងទន្លេសាបចាប់ពីមុខភោជនីយដ្ឋានទន្លេសាប រហូតហួសកោះពេជ្ររួចត្រឡប់មកកន្លែងដើម ។

កុសលបានបន្តថា ការរៀបចំនេះ គឺធ្វើមុនពេលកិច្ចប្រជុំស្ដីពីការចុះហត្ថលេខាលើការលុបបំបាត់ការប្រើប្រាស់គ្រាប់បែកចង្កោម នៅប្រទេសឡាវ ទីក្រុងវៀងចន្ទកាលពីថ្ងៃទី៩-១២វិច្ឆិកា២០១០ ។

កញ្ញារៀបរាប់ពីការរំពឹងទុករបស់ខ្លួននៃកិច្ចប្រជុំនេះថា : "កិច្ចប្រជុំនេះនឹងផ្ដល់នូវភាពយុត្តិធម៌ព្រមទាំងការពារជនរងគ្រោះ និងដែលជនងាយរងគ្រោះពីគ្រាប់បែកចង្កោម ព្រោះយើងមានច្បាប់ស្ដីពីបញ្ហាការប្រើគ្រាប់បែកចង្កោម" ។ កញ្ញា កុសល បានធ្វើការអំពាវនាវចំពោះទិវានេះថា: "យើងទាំងអស់គ្នាចង់ឱ្យរដ្ឋាភិបាលប្រទេសកម្ពុជាចូលរួមក្នុងការមិនប្រើគ្រាប់បែកចង្កោម និងសូមឱ្យបងប្អូនគាំទ្រលើសន្ធិសញ្ញាលុបំបាត់គ្រាប់បែកចង្កោមដើម្បីសង្គមជាតិយើងទាំងអស់គ្នា និងបងប្អូន" ។

**អ៊ឹម សុខន**

# អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញជំរុញព្រះសហគមន៍ខ្មែរ

**ផាត សំភី**

លោកអូលីវីយេ ជ្មិតអីស្លែរ ជាអភិបាលថ្មី នៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញមានប្រសាសន៍ថា លោកគ្រោងនឹង ធ្វើការងារដើម្បីជំរុញខ្មែរតូបនីយកម្ម (ការធ្វើឱ្យទៅជាខ្មែរ)លើព្រះសហគមន៍កាតូលិកនៅក្នុងប្រទេសកម្ពុជា។

កាលពីថ្ងៃទី១៣ វិច្ឆិកា នៅក្នុងពិធីសម្គាល់នៃការផ្ទេរសិទ្ធិទទួលខុសត្រូវជាផ្លូវការលើព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ពីលោកអភិបាល អេមីល ដេតម្ប ត្រូវចូលនិវត្តន៏ទៅលោកអភិបាល អូលីវីយេ ជ្មិតអីស្លែរ។ លោកអភិបាលថ្មីមានប្រសាសន៍ថា លោកចង់ឱ្យមានផ្លាស់ប្តូរ រូបភាពនៃព្រះសហគមន៍កាតូលិកនៅក្នុងប្រទេសកម្ពុជា ដោយការបង្កើនចំនួនលោកបូជាចារ្យនៅក្នុងភូមិភាគ គឺដូចជានៅក្នុងប្រទេស។

នៅក្នុងចំណោមលោកបូជាចារ្យបច្ចុប្បន្ន ចំនួន២២រូបនៅក្នុងព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ គឺមាន២រូបប៉ុណ្ណោះជាជនជាតិខ្មែរ និងមានចំនួនបូជាចារ្យជនជាតិខ្មែរតែ៥រូបប៉ុណ្ណោះនៅក្របខណ្ឌទូទាំងប្រទេស។

លោកអភិបាល អូលីវីយេ បានមានប្រសាសន៍ថា : "យើងចង់កសាងព្រះសហគមន៍កាតូលិកខ្មែរ"។ លោកបានមានប្រសាសន៍ដូច្នេះ ទៅមនុស្សប្រមាណជាង១000នាក់ ដែលបានមកជួបជុំគ្នានៅក្នុងពិធីនោះ នៅឯព្រះវិហារសន្តយ៉ូសែបផ្សាតូចនៅរាជធានីភ្នំពេញ។

លោកអភិបាលបន្ថែមថា : "អាទិភាពរបស់យើងគឺណែនាំយុវជនកាតូលិកឱ្យឆ្លើយតប នឹងការត្រាស់ហៅរបស់ព្រះជាម្ចាស់"។ លោកអភិបាលក៏លើកយកជាគោលការណ៏សំខាន់ដើម្បីទាក់ទាញឱ្យមានលោកបូជាចារ្យជាតិខ្មែរកាន់តែច្រើនឡើងផងដែរ។ លោកអភិបាលមានប្រសាសន៏ថា លោកបូជាចារ្យ និងនិស្សិតទេវវិទ្យាល័យត្រូវតែបង្ហាញនូវគំរូដ៏ល្អនៅក្នុងការរស់នៅរបស់ខ្លួន។

ក្នុងការផ្ញើសារ ដល់គ្រីស្តបរិស័ទក្នុងប្រទេសរវាងជនជាតិខ្មែរ និងជនជាតិវៀតណាម លោកអភិបាលមានប្រសាសន៏ថា : " យើងមានតួនាទីដូចគ្នានៅក្នុងការប្រកាសដំណឹងល្អ"។

លោកអភិបាលអូលីវីយេ មានកំណើតនៅប្រទេសបារាំង សញ្ជាតិខ្មែរនិងមានអាយុ៤0ឆ្នាំ។ លោកត្រូវបានជ្រើសតាំងជាអភិបាលព្រះសហគមន៏កាតូលិក នៅថ្ងៃទី២៤ ខែធ្នូ ២00៩។

នៅក្នុងឱកាសនោះដែរ ឯកឧត្តមមិន ឃិន រដ្ឋមន្ត្រីក្រសួងធម្មការ និងកិច្ចការសាសនា ដែលចូលរួមជាភ្ញៀវកិត្តិយស ស្ងើចសរសើរ ស្នាដៃរបស់លោកអភិបាល អូលីវីយេ ជ្មិតអីស្លែរ ជួយបម្រើដល់ប្រជាជនខ្មែរទន់ខ្សោយ និងក្រីក្រជាពិសេសវិស័យអប់រំ។

គ្រីស្តបរិស័ទទាំងអស់ក្នុងប្រទេសក៏បានសម្តែងការរីករាយជាមួយលោកអភិបាលថ្មីផងដែរ។

លោករ៉ូ បូរ៉ា បានលើកសរសើរលោកអភិបាល អូលីវីយេ ជ្មិតអីស្លែរ ដែលផ្តោតអារម្មណ៏ចំពោះយុវជន និងលើកទឹកចិត្តឱ្យខិតខំធ្វើការងារដើម្បីអភិវឌ្ឍព្រះសហគមន៏។ លោកក៏សង្ឃឹមដែរថាព្រះសហគមន៏នៅកម្ពុជានឹងជួបនូវការប្រឈមមុខថ្មីៗដើម្បីមានឯករាជ្យភាពខាងហិរញ្ញវត្ថុដោយខ្លួនឯងទៅថ្ងៃអនាគត។

ទន្ទឹមគ្នានេះដែរ លោកជិន សុផាត បានកត់សម្គាល់ថា កាលពីមុនលោកអភិបាលអូលីវីយេ ជ្មិតអីស្លែរ សាងសង់សាលាមត្តេយ្យ សាលារៀន និងផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់កសិករ និងអ្នករស់នៅជនបទ។

យុវជនរូបនេះគាំទ្រនូវការលើកឡើងរបស់លោកអភិបាលអូលីវីយេ ជ្មិតអីស្លែរ ដើម្បី "ផ្លាស់ប្តូរ រូបភាពព្រះសហគមន៏កាតូលិកនៅកម្ពុជា"។



Photo : Nith

# ជីវិតជាបូជាចារ្យ គឺការចែកអំណរសប្បាយជាមួយបងប្អូន

**កែវ កញ្ញា**



Photo : DR

បុរសសក់ពណ៌ត្នោតស្លៀកសម្លៀកបំពាក់តឹនុយយ៉ាងសមសួនធ្វើដំណើរយ៉ាងប្រញាប់ប្រញាល់ចេញពីបន្ទប់ប្រជុំមួយទៅកាន់កន្លែងប្រជុំមួយទៀត លោកបូជាចារ្យប្រ៊ុយណូ កូសម៍ បានពោលថា សព្វថ្ងៃនេះលោកមានការរវល់ច្រើនជាមួយគ្រីស្តបរិស័ទ។

លោកប្រ៊ុយណូ ទើបនឹងបានការទទួលខុសត្រូវថ្មីនៅមណ្ឌលសកម្មភាពភ្នំពេញមាន ១១កន្លែង ហើយលោកក៏ទទួលខុសត្រូវនៅព្រះវិហារសន្តយ៉ូសែប(ផ្សារតូច) នៅរាជធានីភ្នំពេញដែរ។

អស់រយៈកាល១២ឆ្នាំ លោករស់នៅក្នុងប្រទេសកម្ពុជា និងទទួលមុខងារជានាយកទេវវិទ្យាល័យកម្ពុជា។ ក្នុងនាមជាសាសនទូតក្រៅប្រទេសលោកបានឱ្យដឹងថា : "ជាពេលវេលាមួយពិសេសសម្រាប់ខ្ញុំក្នុងជីវិតខ្ញុំ១២ឆ្នាំនេះ។ ខ្ញុំ ចាប់អារម្មណ៍មែនទែន និងទទួលបានអំណរសប្បាយពីពួកគេដែរ។ ជីវិតជាបូជាចារ្យ គឺត្រូវចែកអំណរសប្បាយជាមួយ បងប្អូនយើង។"

លោកបូជាចារ្យប្រ៊ុយណូ កូសម៍ មកដល់ប្រទេសកម្ពុជាក្នុងឆ្នាំ១៩៩៥។ លោកមានកំណើតនៅប្រទេសបារាំង។ ក្នុងវ័យ ២៧ឆ្នាំ លោកបានចូលទេវវិទ្យាល័យ ដើម្បីរៀនបួសជាបូជាចារ្យក្នុងក្រុមសាសនទូតក្រៅប្រទេសនៃទីក្រុងប៉ារីស។ ក្រោយពីតែងតាំងជាបូជារ្យនៅឆ្នាំ១៩៩៤ រួចមកលោកត្រូវបានក្រុមចាត់ឱ្យមកប្រទេសកម្ពុជា។

លោកបូជាចារ្យរូបនេះបន្តថា : "ពេលខ្ញុំមកស្រុកខ្មែរ ខ្ញុំអត់ទាន់ស្គាល់អ្នកណាច្បាស់ទាំងលោកទាំងបងស្រី ទាំងគ្រីស្តបរិស័ទ អត់ស្គាល់អ្នកណាសោះនាំឱ្យខ្ញុំពិបាកនិយាយថា ខ្ញុំចង់ធ្វើការងារឱ្យអស់ពីសមត្ថភាពសម្រាប់អស់អ្នកដែលយើងស្រឡាញ់។ ក្នុងនាមខ្ញុំជាគ្រីស្តបរិស័ទ ជាបូជាចារ្យ ខ្ញុំទទួលបេសកកម្មពីព្រះគ្រីស្ត និងពីព្រះសហគមន៍ដើម្បីចែកអំណរសប្បាយជាមួយអ្នកដទៃ។"

ជាមួយនិងបទពិសោធន៍ក្នុងជំនឿ និងការរស់នៅជាមួយបងប្អូនខ្មែរ លោកសម្រេចចិត្តយកសញ្ជាតិកម្ពុជាកាលពីខែកុម្ភៈ ឆ្នាំ២០១០ ។

ក្នុងទឹកមុខញញឹម និយាយបណ្ដើរ ផ្សៀងម៉ោងផងនោះ លោកបានឱ្យដឹងថា ក្នុងមុខងារថ្មីរបស់លោក និងគ្រីស្តបរិស័ទនៅទីនេះនឹងខិតខំប្រកាសដំណឹងល្អដល់អ្នកដទៃដែលមិនស្គាល់ព្រះយេស៊ូ។

"យើងមិនត្រូវបិទខ្លួនយើងតែប៉ុណ្ណឹង តែយើងត្រូវបើកចិត្តគំនិតរបស់យើងទទួលស្វាគមន៍អស់អ្នកដែលមិនជាគ្រីស្តបរិស័ទ។ ខ្ញុំសង្ឃឹមថា នៅប៉ុន្មានខែខាងមុខនេះយើងរិះគិតរួមគ្នាថា យើងអាចធ្វើបានតាមវិធីណា ? មិនមែនឱ្យមានចំនួនច្រើនតែត្រូវធ្វើយ៉ាងណាឱ្យយើងក្លាយជាសាសនទូតដែរ។"

## ប្រតិទិនអភិបូជា

- **ភាសាខ្មែរ** : ព្រះវិហារសន្តយ៉ូសែបភ្នំពេញ (០១២ ៧៨២ ២៤១) ថ្ងៃច័ន្ទ-សៅរ៍ : ព្រឹកម៉ោង៦។ ថ្ងៃអាទិត្យ : ម៉ោង ៨ព្រឹក និងម៉ោង៤រសៀល។
  -កំពង់សោម (០១៦ ៨៤០ ៥៤០) ថ្ងៃច័ន្ទ ថ្ងៃពុធ និងថ្ងៃសុក្រ : ល្ងាចម៉ោង៥។ ថ្ងៃអង្គារ ថ្ងៃព្រហស្បតិ៍ និងថ្ងៃសៅរ៍ : ព្រឹកម៉ោង៦។ ថ្ងៃអាទិត្យ : ម៉ោង ៨ព្រឹក។
  -សៀមរាប (០៦៣ ៩៦៥ ២៨០) ថ្ងៃអាទិត្យ : ម៉ោង៧:៣០ព្រឹក។ ថ្ងៃច័ន្ទ-ថ្ងៃព្រហស្បតិ៍ : ព្រឹក ៦:៣០ម៉ោង។ ថ្ងៃសុក្រ : ម៉ោង ៦:៣០ល្ងាច។
  -បាត់ដំបង (ពេទ្យយាយជី) ថ្ងៃអាទិត្យ : ម៉ោង ៨:០០ព្រឹក។ ថ្ងៃច័ន្ទ : ល្ងាច៦:០០។ ថ្ងៃអង្គារ-សុក្រ : ម៉ោង៦:១៥ ព្រឹក។
- **Français** : 1er et 3ème Samedi du mois à 5:30pm ; 2ème et 4ème Dimanche du mois à 11:00am; à l'église de St. Joseph, #1788B, RN5, PP.
- **English** : - Phnom Penh : Sunday at 10: 00 am; at St. Joseph Church (#1788B, NR5, PP); Saturday at 5: 00 pm, at World Vision Cambodia (#2 St 71, PP); - Sihaknouk Ville : Sunday at 5:00 pm; # Catholic Church St.12 13 Mattapheap; H/P: 016 840 540 (Fr. Werachai); - Siem Reap : Saturday at 6:30 pm; #Catholic Church, No 027 East River Side Street. - Battambang : Saturday: at 6:00 pm at Battamabang Church (Pet Yeaychi), Rumchek 1, Rattanak, H/P: 012 911 147 (Fr. Totet).

# ព័ត៌មាន

## ដំណើរសួរសុខទុក្ខគ្រីស្តបរិស័ទនៅកំពត

កាលពីថ្ងៃទី០៦ ដល់០៧ វិច្ឆិកា ឆ្នាំ២០១០ លោកអភិបាលសុខកុមារ អូលីវីយេ ជ្ជិតអីស្លែរ ជាអភិបាលព្រះសហគន៍ភូមិភាគភ្នំពេញបានចុះទៅដល់ខេត្តកំពត ក្នុងគោលបំណងសួរសុខទុក្ខនឹងជួបប្រជុំជាមួយគណៈកម្មការតាមព្រះសហគមន៍នីមួយៗនៅមណ្ឌលសកម្មភាពកំពត។ នៅខេត្តកំពតមានព្រះសហគមន៍បួន និងមានលោកបូជាចារ្យទទួលខុសត្រូវពីរនាក់ គឺលោកអ៊ុនសុន លោកលូកា។ ពេលនោះដែរលោកអភិបាល ក៏បានជួបជាមួយយុវជនយុវនារីដើម្បីលើកទឹកចិត្តឱ្យខំយកចិត្តទុកដាក់លើការសិក្សារៀនសូត្រហើយលោកមានជាសំភារៈសិក្សាជាមួយចំនួនឱ្យទៅពួកគេដែរ ។

គ្រីស្តបរិស័ទនឹងបូជាចារ្យមានការសប្បាយរីករាយយ៉ាងខ្លាំងចំពោះវត្តមានរបស់លោកអភិបាលថ្មី។ លោកអភិបាលបានផ្តលអនុសាសន៍ថា "គោលដៅ រួមគឺធ្វើយ៉ាងណាឱ្យព្រះសហគមន៍រីកចម្រើននឹងបន្តភាពរីកចម្រើនតទៅមុខទៀត"។ នេះគឺជាអនុសាសន៍របស់លោកអភិបាលសុខកុមារ



អូលីវីយេ ជ្ជិតអីស្លែរ ជូនទៅព្រះសហគមន៍ដែលមានក្នុងខេត្ត កំពត ។

**ប៉ែត សុធិរិទ្ធ**

## បេសកកម្មរបស់លោកអភិបាលនៅមណ្ឌលចំប៉ា



លោកអភិបាលភូមិភាគភ្នំពេញបានទទួលព្រះសហគមន៍ជិត ៤០ព្រះសហគមន៍។ ដូច្នេះហើយលោកតែងតែឆ្លៀតពេលដើម្បីចុះសួរសុខទុក្ខតាមព្រះសហគមន៍នីមួយៗ។

យ៉ាងណាមិញកាលពីថ្ងៃទី២៥ ដល់២៨ វិច្ឆិកា ២០១០ លោកអភិបាលសុខកុមារ អូលីវីយេ ជ្ជិតអីស្លែរ ជាអភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញបានចុះសួរសុខទុក្ខគ្រីស្តបរិសទ នៅមណ្ឌលសកម្មភាពចំប៉ា ដែលមានលោកបូជាចារ្យឡេវ៉ាន់ទីន ជាអ្នកទទួលខុសត្រូវ។ នៅពេលនោះដែរលោកអភិបាល មិនត្រឹមតែទៅដើម្បីសួរសុខទុក្ខបងប្អូនប៉ុណ្ណោះទេ គឺលោកក៏បានជួបប្រជុំជាមួយគណៈកម្មការតាមព្រះសហគមន៍នីមួយៗមាននៅមណ្ឌលសកម្មភាពចំប៉ា។ ទង្វើទាំងនេះពិតជាធ្វើឱ្យគ្រីស្តបរិស័ទទទួលបាននូវភាពកក់ក្តៅយ៉ាងខ្លាំង។

ជាការពិតណាស់ទោះបីជាលោកអភិបាលមានភាពមមាញឹកយ៉ាងណាក៏ដោយលោកនៅតែយកពេលវេលាដ៏តិចតួចជួបជាមួយបងប្អូនតាមមណ្ឌលសកម្មភាពនីមួយៗ។ លោកក៏បាន បញ្ជាក់ឱ្យគ្រីស្តបរិស័ទខិតខំយកចិត្តទុកដាក់ធ្វើយ៉ាងណាឱ្យព្រះសហគមន៍រីកចម្រើន និងមានទំនាក់ទំនងជាមួយគ្នាយ៉ាងជិតស្និទ្ធ។

**ប៉ែត សុធិរិទ្ធ**

## កម្មវិធីជនពិការអន្តជាតិលើកទី២៨ ឆ្នាំ២០១០ នៅតាកែវ

កាលពីថ្ងៃច័ន្ទ ទី២៩ វិច្ឆិកា ឆ្នាំ២០១០កន្លង មកថ្មីៗនេះនៅក្នុងវត្តថ្នឹកជ្រុំ ខេត្តតាកែវ បានប្រារព្ធកម្មវិធីជនពិការអន្តជាតិលើកទី២៨ ឆ្នាំ២០១០ ជំនួសឱ្យថ្ងៃទី០៣ ធ្នូ ឆ្នាំ២០១០ ក្រោមប្រធានបទ "យើងទាំងអស់គ្នាបន្តជំរុញពីការអនុវត្តន៍លើការការពារ និងលើកកម្ពស់សិទ្ធិជនពិការប្រកបដោយប្រសិទ្ធភាព"។

ក្នុងឱកាសនោះ មានការចូលរួមពីលោកសោម អ៊ុំមុន្នីរ៉ា (ប្រធានមន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តតាកែវ) លោកអភិបាល សុខកុមារ អូលីវីយេ ជ្ជិតអីស្លែរ ជាអភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ និងជាអគ្គទីប្រឹក្សាអង្គការឌីកហ្វី (DYCFE) លោកស្រីគា សុភ្ញ អភិបាលស្រុកត្រាំកក់ បងប្អូនជនពិការអាណាព្យាបាល បងប្អូនជនពិការទូទាំងស្រុក ត្រាំកក់ ព្រមទាំងលោក លោកស្រីដែលជាតំណាងអង្គការស្ថាប័នដែលពាក់ព័ន្ធជាច្រើនរូបទៀត។ ក្រោមផ្ទៃមេឃស្រលះរួមជាមួយបរិយា កាសដ៏សែនមនោរម្យ បងប្អូនជនពិការបង្ហាញទុកនូវស្នាម ញញឹម និងមានភាពកក់ក្តៅគ្រប់ៗគ្នាដោយសារតែអង្គការ ឌីកហ្វីសហការជាមួយលោកអភិបាលសុខកុមារ អូលីវីយេ ជ្ជិតអីស្លែរ និងសប្បុរសជន ព្រមទាំងអង្គការស្ថាប័នមួយទៀតបានបង្កើតកម្មវិធីនេះឡើងដើម្បីពួកគេ។

កុមារាម៉ែន យ៉ាំ បន្ទាប់ពីឡើងនិយាយពីជីវិតពិតជាជនពិការរួចមកនាងក៏បានផ្តលមតិបញ្ជាក់ថា : "ខ្ញុំជាជនពិការដែលអស់សង្ឃឹមជាយូរមកហើយ។ ខ្ញុំចង់



រៀនតែគ្មានអ្នកជួយផ្តល់កម្លាំងចិត្ត ឬផ្តត់ផ្គង់ខ្ញុំទេ។ ខ្ញុំតែងតែបួងសួងសុំឱ្យរូបខ្ញុំមានការជោគជ័យលើអ្វីមួយដូចជាឱ្យខ្ញុំបានរៀនជាដើមតែពេលនេះខ្ញុំសម្រេចគោលបំណងហើយ នៅក្រោយពេលខ្ញុំបានជួបនឹងអង្គការឌីកហ្វី ព្រោះបុគ្គលិកអង្គការទាំងអស់បានលើកទឹកចិត្តខ្ញុំ ផ្តល់កម្លាំងចិត្ត ផ្តល់ថវិកាឱ្យខ្ញុំបានទៅរៀននឹងគេ។ ពេលនេះខ្ញុំមានបំណងប្រាថ្នាមួយទៀតគឺ សុំឱ្យមានសប្បុជន អង្គការស្ថាប័នបន្តជួយដល់ជនពិការទាំងអស់កំពុងរង់ចាំជួយពីអស់លោក"។ ក្នុងកម្មវិធីលោកសោម អ៊ុំមុន្នីរា នឹងលោកអភិបាលសុខកុមារ អូលីវីយេ ជ្ជិតអីស្លែរ ក៏បានជំរុញ និងលើកទឹកចិត្តដល់ជនពិការទាំងអស់ឱ្យបន្តយកចិត្តទុកដាក់លើការរៀនសូត្រឱ្យបានល្អព្រោះសង្គមត្រូវការបងប្អូនជនពិការមិនដែលបោះបង់ឡើយ។

**ប៉ែត សុធិរិទ្ធ**



Photo : S. Philong

# អ្នកថតរូបវ័យក្មេង : រូបថតគឺជាសិល្បៈ

**ខាន់ ភីរម្យ**

ការថតរូបគឺជាវិជ្ជាជីវៈសិល្បៈ និងការកែច្នៃមួយប្រភេទ។ បើតាមការអះអាងរបស់អ្នកថតរូប វ័យ២៤ឆ្នាំ ដែលទទួលពានរង្វាន់នៅក្នុងកម្មវិធី "ទន្សាយនៅក្នុងពន្លឺភ្លើងរបស់អ្នក" នៅក្នុងមហោស្រពរូបថតអង្គរកាលពីថ្មីៗកន្លងទៅនេះ ។

លោកសុវណ្ណ ភីឡុង អ្នកទទួលជ័យលាភីបានឱ្យដឹងថា រូបថតមួយសន្លឹក វាមានលក្ខណៈដូចផ្ទាំងគំនូមួយផ្ទាំងដែរ។ ប៉ុន្តែវាខុសគ្នានៅត្រង់ថា រូបថតគេផ្ដិតរូបភាពដោយបច្ចេកវិទ្យា។

លោកបានបន្តទៀតថា រូបថតគឺជាស្នាដៃសិល្បៈមួយប្រភេទ ហើយវាគឺជាការបញ្ឈប់សកម្មភាពអ្វីមួយ ដែលអ្នកថតរូបចង់បញ្ឈប់វា។ ហើយស្នាដៃ នៃការថតរូបគេអាចនឹងប្រើប្រាស់បានច្រើនយ៉ាង។

លោកបានបញ្ជាក់ថា: "មធ្យោបាយនៃការថតមានច្រើនណាស់ តែស្នាដៃដែលខ្ញុំថតហើយទទួលបានជ័យលាភីក្នុងមហោស្រពរូបភាពអង្គរ ក្រោមប្រធានបទ "ទន្សាយនៅក្នុងពន្លឺភ្លើងរបស់អ្នក" គឺខ្ញុំថតនៅពេលយប់រហូតដល់ម៉ោង ៤ ទៅ ម៉ោង ៥ ព្រឹកដោយប្រើប្រាស់ម៉ាស៊ីនថត ជាមួយនឹងពន្លឺភ្លើងម៉ូតូ និងកុំព្យូទ័រយួរដៃរបស់ខ្ញុំតែប៉ុណ្ណោះ"។

លោកបានបន្តទៀតថា ក្រៅពីមធ្យោបាយ និងការកែច្នៃដែលធ្វើឱ្យលោកទទួលបានជោគជ័យខាងលើ វានៅមានមធ្យោបាយ និងការកែច្នៃជាច្រើនទៀតដែលគេអាចនឹងចាប់យករូបភាពបានច្រើន និងធ្វើឱ្យជោគជ័យផងដែរ។

លោកបានបន្តទៀតថា រូបថតគេអាចប្រើប្រាស់វា បានច្រើនយ៉ាងដូចជា ជាស្នាដៃសិល្បៈ ជាផលិតផលអនុស្សាវរីយ៍ ជាស្នាដៃឯកសារ ហើយក៏ជាផលិតផលដែលអាចប្រើប្រាស់នៅលើទំព័រសារព័ត៌មានផងដែរ។

ស្នាដៃដែលលោកសុវណ្ណ ភីឡុង បានទទួលជ័យលាភីនេះ គឺជារូបថតចំនួន ១៧ សន្លឹកដែលថត និងពិពណ៌នាអំពីជីវភាពប្រជាពលរដ្ឋកម្ពុជានៅពេលរាត្រី។ ស្នាដៃថតរូបរបស់លោកបានត្រូវគេជ្រើសរើសពីស្នាដៃរបស់អ្នកថតរូបវ័យក្មេងប្រមាណជា ៣០នាក់ មកពីប្រទេសជាង ១០ នៅអាស៊ីក្នុងអំឡុងកម្មវិធីសិក្ខាសាលារយៈពេលមួយសប្ដាហ៍ ដែលរៀបចំឡើង នៅក្នុងខេត្តសៀមរាបកាលពីពេលថ្មីៗកន្លងទៅ។

## កំណាព្យល្បែងប្រជាប្រិយខ្មែរ




បាយឡុកបាយឡ ជិះសេះធាងចេក លេងបង្ហោះខ្លែង បូតសណ្ដែក លោតអន្ទាក់ ស្ដេចចង់ ស្វាដណ្ដើមទី លោតអង្រែ លាក់កន្សែង ចាប់កូនខ្លែង ទាញព្រ័ត្រ ទាត់សី បោះអង្គុញ បោះឈូង លាក់ធ្យូង វាយក្អម លេងរែក លេងអុក ចត្រង្គ បោះឡូត បាយខុំ បិទពួន គ្រែះ ចោលហ៊ីង...សុទ្ធសឹងជា ល្បែងប្រជាប្រិយខ្មែរមានតាំងពីយូរយារណាស់មកហើយ ។

យើងអាចស្វែងយល់ពីល្បែងប្រជាប្រិយទាំងនេះតាមរយៈអត្ថបទកំណាព្យដ៏ពីរោះរណ្ដំ និងរូបភាពពណ៌យ៉ាងល្អវិចិត្រ និងរស់រវើក។ ចំពោះកុមារ សៀវភៅនេះនឹងជួយពួកគេឱ្យស្គាល់ឈ្មោះនិងយល់ដឹងអំពីល្បែងដែលគេកំពុងលេង និងល្បែងដទៃទៀតដែលគេពុំទាន់ស្គាល់។ ចំពោះមនុស្សធំ វានឹងរំឭកអនុស្សាវរីយ៍របស់យើងទាំងអស់គ្នាកាលនៅក្មេងដែលពេលខ្លះយើងបានភ្លេចទៅហើយ ។

ស្នាដៃនេះនិពន្ធដោយ លោកវ៉ែន សុន និងគូររូបដោយ យុន សុវណ្ណរិទ្ធី និងត្រូវបានបោះពុម្ពនៅ២០០៥ ដោយអង្គការរូមធូរីដ។

## សិក្សាចក្រ លេខ៨_៩




ក្នុងមជ្ឈដ្ឋានអ្នកសិក្សាស្រាវជ្រាវ គេមិនមើលរំលងឯកសារដ៏មានតម្លៃនេះឡើយ។ សិក្សាចក្រ គឺទស្សនាវដ្ដីប្រចាំឆ្នាំដែលប្រមូលផ្ដុំទៅដោយអត្ថបទស្រាវជ្រាវរបស់អ្នកសិក្សាទាំងជំនាន់ចាស់និងជំនាន់ថ្មី ទាំងនៅក្នុងប្រទេស និងក្រៅប្រទេស។ ស្នាដៃនេះបោះពុម្ពជាបីភាសា (ខ្មែរ អង់គ្លេស និងបារាំង) ជួយរួមចំណែកផ្ដល់ព័ត៌មានថ្មីៗ លើប្រធានបទខុសៗគ្នាជាច្រើន : វប្បធម៌ សាសនា សិល្បៈ ស្ថាបត្យកម្ម ប្រវត្តិសាស្ត្រជាតិពន្ធុ...

ចំណែកសិក្សាចក្រ លេខ៨-៩ នេះជាលេខដែលនិយាយពីពុទ្ធសាសនាប៉ុណ្ណោះ។ យើងអាចអានប្រធានបទដូចជា: "ព្រះពុទ្ធសាសនា ពាណិជ្ជកម្ម និងនយោបាយ" "ការកែទម្រង់ឆ្ពោះទៅកាន់ទំនើបនិយមក្នុងប្រវត្តិពុទ្ធសាសនាខ្មែរ" "នាទីរបស់ពុទ្ធសាសនបណ្ឌិតក្នុងដំណើរការបង្កើនទំនាក់ទំនងពុទ្ធចក្រខ្មែរ-លាវ" និង "ព្រះពុទ្ធសាសនា និងការអភិវឌ្ឍសង្គមក្នុងប្រទេសកម្ពុជាចាប់តាំងពីការផ្ដួលរំលំរបបប៉ុលពត" -ល-។

ស្នាដៃនេះបោះពុម្ពនៅឆ្នាំ២០០៧ ដោយមជ្ឈមណ្ឌលខេមរសិក្សា និងតម្លៃ ៤ដុល្លារ។ **ហួត សុជាតា**

# អធិប្បាយព្រះបន្ទូលថ្ងៃអាទិត្យ



## ខែធ្នូ ២០១០ អធិប្បាយព្រះបន្ទូលថ្ងៃអាទិត្យ ដោយលោកឪពុកឡាំងសង់ សេនីយ៍ឆាល

ខែធ្នូនេះ អត្ថបទគម្ពីររៀបរាប់អំពីលោកយ៉ូហាន បាទីស្ត លោកយ៉ូសែប និងព្រះនាងម៉ារី ដែលរៀបចំផ្លូវទទួលព្រះយេស៊ូ។ អ្នកទាំងបីជួបឧបសគ្គខ្លះដែលត្រូវពុះពារឱ្យបានជួបព្រះយេស៊ូដែលជាព្រះសង្គ្រោះយាងមកជា ប្រយោជន៍ ដល់មនុស្សលោក។

**ថ្ងៃអាទិត្យទី ២ ក្នុងរដូវរង់ចាំ ព្រះគ្រីស្តយាងមក ឆ្នាំ ក (ថ្ងៃទី៥ ខែធ្នូ ២០១០)** ***(មថ ៣:១-១២)***

មុនដំបូង លោកយ៉ូហានបាទីស្តអញ្ជើញមនុស្សដែលមកស្តាប់គាត់ ដើម្បីរកវិធីដោះស្រាយឧបសគ្គមួយដែលគេគិតថា គ្មានការសង្គ្រោះទេនៅលើលោកនេះ។ ជាធម្មតា មនុស្សជាច្រើនគិតថា ខ្លួនជាមនុស្សល្អឥតខ្ចោះ គ្មានបាបសោះ។ មនុស្សផ្សេងទៀតគិតថា ខ្លួនអាចសង្គ្រោះខ្លួនឯងបានដោយសារធ្វើបុណ្យច្រើន។ គំនិតទាំងនេះជាឧបសគ្គ ដែលឃាត់គេមិនឱ្យជួបព្រះសង្គ្រោះ។ ព្រះយេស៊ូយាងមកសម្រាប់មនុស្សដែលស្រេកឃ្លានការសង្គ្រោះ និងទទួលស្គាល់ ពីបាបរបស់ខ្លួន ហើយមានចិត្តសុភាពរាបសា។

**ថ្ងៃអាទិត្យទី ៣ ក្នុងរដូវរង់ចាំ ឆ្នាំ ក (ថ្ងៃទី១២ ខែធ្នូ ២០១០)** ***(ម៉ាថាយ ១១:២-១១)***

ឧបសគ្គមួយទៀត ដែលលោកយ៉ូហានបានពុះពារ គឺការសង្ស័យ។ ក្នុងអត្ថបទនេះ ហាក់ដូចជាលោកយ៉ូហានបាទីស្ត បាត់ជំនឿដោយមិនទទួលស្គាល់ថា មានព្រះសង្គ្រោះ។ ទោះជាយ៉ាងណា ព្រះយេស៊ូចាត់ទុកថា ក្នុងពិភពលោក ទាំងមូល លោកយ៉ូហាន បាទីស្ត មានឋានៈធំជាងគេ។ ជំនឿរបស់លោកយ៉ូហានបាទីស្តបានឈ្នះការសង្ស័យ។

**ថ្ងៃអាទិត្យទី ៤ ក្នុងរដូវរង់ចាំ ឆ្នាំ ក (ថ្ងៃទី១៩ ខែធ្នូ ២០១០)** ***(ម៉ាថាយ ១:១៨-២៤)***

មុនពេលព្រះយេស៊ូយាងមកក្នុងលោកនេះ ឧបសគ្គមួយទៀតដែលព្រះជាម្ចាស់បានឈ្នះ គឺចិត្តរបស់លោក យ៉ូសែប ដែលមិនចង់ទទួលនាងម៉ារីដែលមានផ្ទៃពោះ។ បច្ចុប្បន្ននេះ នៅតែមានឧបសគ្គនេះដដែលកើតឡើង ដូចព្រះ នាងម៉ារីដែរ ឧទាហរណ៍ មានបុរសខ្លះដែលលែងលះសង្សារដែលមានផ្ទៃពោះ ឬជំរុញគេឱ្យពន្លូតកូន។ ប៉ុន្តែ ជីវិតមនុស្សមានតម្លៃណាស់ ទោះបីជាជីវិតរបស់មនុស្សតូចតាចទន់ខ្សោយយ៉ាងណាក៏ដោយ។ យើងជាកាតូលិកការពារជីវិតមនុស្សពីដើមដំបូង រហូតដល់ទីបញ្ចប់។

**បុណ្យលើកតម្កើងព្រះយេស៊ូប្រសូត (ថ្ងៃទី២៥ ខែធ្នូ ២០១០)** ***(លូកា ២:១-១៤)***

ព្រះយេស៊ូបានប្រសូតក្នុងឋានៈជាមនុស្សក្រីក្របំផុត។ ដូច្នេះហើយ ព្រះអង្គបានបង្ហាញពីការចាប់អារម្មណ៍ និងពីសេចក្តីស្រលាញ់របស់ព្រះអង្គចំពោះមនុស្សលោក។ ម្យ៉ាងទៀត ព្រះអង្គបញ្ជាក់ថា ភាពក្រីក្រមិនមែនជាឧបសគ្គមួយដែលបណ្តាលឱ្យមានមនុស្សឃ្លាតឆ្ងាយពីព្រះជាម្ចាស់ទេ។ អ្នកក្រីក្រជាច្រើនគិតថា ព្រះជាម្ចាស់មិនចាប់អារម្មណ៍ នឹងពួកគេទេហើយដាក់បណ្តាសសាដល់គេ។ តាមការពិត បុណ្យព្រះយេស៊ូប្រសូតបង្ហាញពីសេចក្តីស្រលាញ់យ៉ាងខ្លាំង បំផុតរបស់ព្រះយេស៊ូសម្រាប់អ្នកកម្សត់ទុគិត។ ជាងនេះទៅទៀត គ្រីស្តបរិស័ទដែលជាតំណាងព្រះយេស៊ូនៅលើលោកនេះ បានបង្ហាញការចាប់អារម្មណ៍ចំពោះអ្នកតូចតាចដូចព្រះអង្គ។

**បុណ្យលើកតម្កើងព្រះរាជវង្ស (ថ្ងៃទី២៦ ខែធ្នូ ២០១០)** ***(ម៉ាថាយ ២:១៣-១៥.១៩-២៣)***

"ព្រះរាជវង្ស" ឬ "គ្រួសារដ៏វិសុទ្ធ" គឺជាក្រុមគ្រួសាររបស់ព្រះយេស៊ូ មានលោកយ៉ូសែប នាងម៉ារី និងព្រះកុមារយេស៊ូ។ គ្រួសារដ៏វិសុទ្ធត្រូវតស៊ូ ពុះពារឧបសគ្គជាច្រើន មានដូចជាភាពក្រីក្រ ការតស៊ូ ការបន្ទាបខ្លួន ដើម្បីការពារជីវិត និងលះបង់ប្រយោជន៍ផ្ទាល់ខ្លួនដល់អ្នកដទៃ។ គ្រួសារដ៏វិសុទ្ធនេះចេះរស់នៅដោយចេះសម្របសម្រួលគ្នា។ លោកយ៉ូសែបមានការទទួលខុសត្រូវក្នុងតួនាទីជាស្វាមីដ៏ល្អរបស់នាងម៉ារី។ រួមជាមួយនាង លោកបានអប់រំប្រៀនប្រដៅកុមារយេស៊ូ ដោយបង្ហាញអំពីរបៀបរស់នៅឱ្យចេះតស៊ូ និងពឹងផ្អែកលើព្រះជាម្ចាស់។

---

**កំណាព្យ**

## សម្លេងស្ត្រីមេផ្ទះ

(បទកាកគតិ)

ស្ត្រីទាំងឡាយ មេផ្ទះគ្រប់កាយ ប្រឹងស្រាយបញ្ហា
ព្រឹកព្រាងថ្ងៃរះ ជះសូរិយា ហត្ថទាំងទ្វេហា
ឥតមានពេលស្រាន្ត។

ចាប់រៀបចំផ្ទះ ដាក់ទៅចោលជ្រះ ជម្រះភូមិស្ថាន
ណាមើលថៃកូន បងប្អូនសណ្តាន ទុកដាក់ចានក្បាន
ចង្ក្រានបាយផង។

ឯម្ហូបអាហារ ត្រូវធ្វើយ៉ាងណា ទើបសមបំណង
ខ្លាចត្រូវមាត់ប្តី ឆីមិនទំនង ប្រាក់តិចតួចផង
ម្តងស្លម្តងអាំង។

តម្រូវចិត្តប្តី ឯកូនប្រុសស្រី គ្មានអ្វីប្រឆាំង
ខ្លួនជាមេផ្ទះ ជម្នះរារាំង បុកម្ហូរក្រសាំង
ទុកហូបខ្លួនឯង។

សន្សំត្បិតត្បៀត គ្រប់គ្រងចេះទៀត ឆ្លៀតរកកន្លែង
ដាំជីស្លឹកក្រៃ ម្ទេសខ្ញីរំដេង ក្បែរផ្ទះសម្បែង
ក្រែងគ្រាន់បេះស្ល។

ខោអាវរហែក ដេរប៉ះបំណែក ចែកជិតឱ្យល្អ
បោកគក់យ៉ាងស្អាត សំអាតក្អែលក ទោះពណ៌ខ្មៅស
ក៏ដេរឱ្យហើយ។

ថៃទ្រព្យរបស់ ទោះតិចតួចសោះ មិនឱ្យបាត់ឡើយ
រក្សាឱ្យគង់ ក្នុងក្រៅក៏ដោយ នាទីនេះហើយ
ភារៈភរិយា។

សូមកុំគិតថា មេផ្ទះនេះណា គ្មានទេការងារ
ទាំងអប់រំកូន សណ្តូនវេលា ប្រដៅស្ងួនភ្ងា
ងារជាមាតា។

កូនល្អត្រងត្រាប់ ស្វាមីក៏គាប់ ភ័ព្វព្រេងវាសនា
កូនខុសគន្លង ញាតិផងមោហា ស្វាមីសាវ៉ា
មាតារីងរៃ។

មេផ្ទះគ្រប់គ្នា ប្រាថ្នាសោភា គ្មានទេទុក្ខភ័យ
តែងតែបួងសួង សូមសុខសួស្តី ដើម្បីរស្មី
មង្គលគ្រួសារ។

**និពន្ធដោយអ្នកស្រី ខុង ណារី** **ថ្ងៃទី១៧ វិច្ឆិកា ២០១០**

# សកម្មភាពរបស់ព្រះសហគមន៍កាតូលិក នៅខែវិច្ឆិកា

ជីម មីហៀវស្ដី និងភីឡុង

*ខែមុននេះ ព្រះសហគមន៍កាតូលិក មានពិធីគោរពអធិធាតុសន្តយ៉ូហាន ដុនបូស្កូ និងការផ្ទេរភារកិច្ចពីលោកអភិបាលអេមីលទៅលោកអភិបាលអូលីវីយេ ។*



លោកអភិបាលអូលីវីយេជួបជាមួយរដ្ឋមន្ត្រីក្រសួងកិច្ចការសាសនា



លោកអភិបាលអេមីល ដេតម្ប ប្រគល់ដំបងជាសញ្ញានៃសិទ្ធជូនលោកអភិបាលសុខកុមារ អូលីវីយេ ផ្មិតអីស្ត្លែរ



លោកអភិបាលអូលីវីយេ ថតរូបជាមួយលោកបូជាចារ្យនានានៅថ្ងៃផ្ទេរសិទ្ធកាលពីថ្ងៃទី១៣ វិច្ឆិកា



គ្រីស្តបរិស័ទជូនពរលោកអភិបាលសុខកុមារ អូលីវីយេ ផ្មិតអីស្ត្លែរ



គណៈអធិបតីរួមមានលោកអភិបាល សុខកុមារ អូលីវីយេ ចូលរួមគោរពអធិធាតុសន្តយ៉ូហាន បូស្កូ កាលពីថ្ងៃទី៣ ធ្នូ នៅសាលាដុងបូស្កូ ភ្នំពេញថ្មី រាជធានីភ្នំពេញ។



លោកអភិបាលព្រះសហគមន៍កាតូលិក សុខកុមារ អូលីវីយេ ផ្មិតអីស្ត្លែរ ស្មិងស្មាធិ៍គោរពអធិធាតុសន្តយ៉ូហាន ដុងបូស្កូ។

## វិទ្យុវេរីតាស់អាស៊ី (RVA) ផ្នែកភាសាខ្មែរផ្សាយរយៈពេល ៥៧នាទី ជារៀងរាល់ថ្ងៃតាមរយៈ រលកធាតុអាកាសខ្លី (Short Wave = sw) គឺ :

~ពេលព្រឹក ពីម៉ោង ៨:៣០នាទី ដល់ម៉ោង ៨:៥៧នាទី ផ្សាយក្នុងរលកធាតុអាកាស ១៥២៨០ គីឡូហឺតស៍ ត្រូវនឹងកម្ពស់ ១៩,៦៣ ម៉ែត្រ។

~ពេលរសៀល ពីម៉ោង ៥:០០នាទី ដល់ម៉ោង ៥:៣០នាទី ផ្សាយក្នុងរលកធាតុអាកាស ១១៨៥០ គីឡូហឺតស៍ ត្រូវនឹងកម្ពស់ ២៥,៣២ ម៉ែត្រ។

ស្តាប់វិទ្យុវេរីតាស់ អាស៊ី (RVA)លោកអ្នកនឹងទទួលបានចំណេះដឹង អំពីជីវិត និងសង្គម និងព័ត៌មាននានាពីព្រះសហគមន៍កាតូលិកនៅកម្ពុជា។

## កម្មវិធីវិទ្យុព្រះសហគមន៍កាតូលិក

### អ្នកចូលរួមកម្មវិធីអេម៉ានូអែល "សម្លេងពីព្រះសហគមន៍កាតូលិក" ខែធ្នូ

-ថ្ងៃអាទិត្យ ទី០៥ ខែធ្នូ ឆ្នាំ២០១០ : អាទិត្យទី២ ក្នុងរដូវរង់ចាំចូលរួមដោយលោកបូជាចារ្យ ប្រ៊ុយណូ នៅវិហារសន្តយ៉ូសែប ហៅផ្សារតូចរាជធានី ភ្នំពេញ។

-ថ្ងៃអាទិត្យ ទី១២ ខែធ្នូ ឆ្នាំ២០១០ : អាទិត្យទី៣ ក្នុងរដូវរង់ចាំចូលរួមដោយលោកបូជាចារ្យអ៊ុំ អ៊ីន ដុន នៃក្រុមសហជីវិនព្រះយេស៊ូ។

-ថ្ងៃអាទិត្យទី១៩ ខែធ្នូ ឆ្នាំ២០១០ : អាទិត្យទី៤ ក្នុងរដូវរង់ចាំ ចូលរួមដោយលោកអ៊ីវ៉ាន ក្រុមសាសនទូត យេរ៉ូម៉ាល់។

-ថ្ងៃអាទិត្យទី២៦ ខែធ្នូ ឆ្នាំ២០១០ : បុណ្យព្រះយេស៊ូសូត្រចូលរួមដោយលោកអភិបាលអន់តូនី ជាអភិបាល ភូមិភាគកំពង់ចាម។

### "ខ្ញុំត្រូវការអ្នក" ខែតុលា (FM 99.5 Mhz ច័ន្ទ,អង្គារ ម៉ោង១០-១១ព្រឹក)

ថ្ងៃទី០៦ ធ្នូ : យុវជន និងឥរិយាបទនៅទីប្រជុំជន។ ថ្ងៃទី០៧ ធ្នូ : យុវជន និងការងារសហគមន៍។ ថ្ងៃទី១៣ ធ្នូ : សក្តានុភាពយុវវ័យក្នុងសង្គម។ ថ្ងៃទី១៤ ធ្នូ : យុវជន និងភាពជោគជ័យក្នុងអាជីវកម្ម។ ថ្ងៃទី១៨ ធ្នូ : កល្យាណមិត្ត។ ថ្ងៃទី២០-២១ ធ្នូ: យុវវ័យក្នុងរដូវកាលព្រះយេស៊ូប្រសូត។ ថ្ងៃទី២៧ ធ្នូ : ផឹកស្រាបំបាត់ទុក្ខ?។ ថ្ងៃទី២៨ ធ្នូ : ជប់លៀង ហ៊ឺហាផឹកសុរាឬ?។

សូមបញ្ជាក់ថា ប្រធានបទទាំងនេះនឹងមានការចូលរួមបកស្រាយពីវាគ្មិនដែលមានបទពិសោធន៍ និងជំនាញច្បាស់លាស់។**សូមកុំភ្លេចតាមដាន!**

## ការងារប្រចាំខែ

- ថ្ងៃទី៨ ធ្នូ : ពិធីបុណ្យព្រះនាងម៉ារីគ្មានជំពាក់បាបកម្មយ៉ាងឱឡារិកនិងហែរព្រះនាងម៉ារីសូត្រផ្គាំនៅព្រះវិហារសន្តយ៉ូសែបហៅផ្សារតូចវេលាម៉ោង៦ និង១៥នាទីល្ងាច។
- ថ្ងៃទី១១-១២ ធ្នូ : សិក្ខាសាលាសម្រាប់យុវជនមណ្ឌលសម្ភភាពភ្នំពេញក្រោមប្រធានបទ "យើងជាគ្រីស្តបរិស័ទនៅក្នុងសង្គមរបស់យើង" ដែលមានយុវជនចូលរួមចំនួន ៦០នាក់។
- ថ្ងៃទី១១-១៥ ធ្នូ : យុវជនសិង្ហបុរីចំនួន ២០នាក់ និងមកធ្វើការនៅចំការភូមិវល្លិ៍ ចាប់ពីថ្ងៃទី ១១ ដល់ទី១៨ ខែធ្នូ។
- ថ្ងៃទី១៣-១៤ ធ្នូ : អង្គការការីតាសកម្ពុជាប្រជុំនៅព្រះវិហារសន្តមីកាអ៊ែល (កំពង់សោម)ដែលមានអ្នកចូលរួមចំនួន ១៥០នាក់។
- ថ្ងៃទី១៥ ធ្នូ : ព្រះវិហារកំពង់សោមចែកអំណោយដល់ពិរុទ្ធជននៅពន្ធនាគារ ខេត្តព្រះសីហនុ ១៧០នាក់។
- ថ្ងៃទី១៧ ធ្នូ : ពិធីទទួលស្វាគមន៍លោកអភិបាលសុខកុមារ អូលីវីយេ មកសួរសុខទុក្ខគ្រីស្តបរិស័ទនៅព្រះវិហារ កោះកុង ខេត្តកោះកុង។
- ថ្ងៃទី១៨ ធ្នូ : ពិធីទទួលស្វាគមន៍លោកអភិបាលសុខកុមារអូលីវីយេ មកសួរសុខទុក្ខគ្រីស្តបរិស័ទនៅព្រះវិហារសន្ត មីកាអែល និងគណៈគ្រប់គ្រងលោកគ្រូ អ្នកគ្រូ ព្រមទាំងសិស្សានុសិស្សនៃសាលាបច្ចេកទេសដុនបូស្កូ ខេត្តព្រះសីហនុ។
- ថ្ងៃទី១៨ ធ្នូ: ពិធីទទួលអគ្គសញ្ញាលើកលែងទោសនៅព្រះវិហារយ៉ូសែប (ផ្សារតូច) វេលាម៉ោង ៤រសៀល។
- ថ្ងៃទី១៩ ធ្នូ : លោកអភិបាលសុខកុមារ អូលីវីយេ ផ្ទឹតអ៊ីស្ទែរ ថ្វាយអភិបូជានៅព្រះវិហារសន្តមីកាអែល កំពង់សោម។
- ថ្ងៃទី២០ ធ្នូ : ព្រះវិហារតំបន់កំពតចែកអំណោយដល់ពិរុទ្ធជននៅពន្ធធនាគារ ខេត្តកំពត ចំនួន ៣៧៥នាក់។
- ថ្ងៃទី២៤ ធ្នូ : រាត្រីបុណ្យព្រះយេស៊ូប្រសូត ថ្វាយអភិបូជាដែលមានការអញ្ជើញចូលរួមពីលោកអភិបាលសុខកុមារអូលីវីយេ។

### ការិយាល័យរថាំ និងវប្បធម៌

(ភូមិភាគបាត់ដំបង) មានទទួលប៉ាក់សម្លៀកបំពាក់គ្រប់ប្រភេទក្នុងតម្លៃសមរម្យ។
ទំនាក់ទំនងកញ្ញាសួន ប៊ុណ្ណារេត លេខទូរស័ព្ទ : ០១៧ ៣៤ ២៨ ៣៤។ សូមអរគុណ!
Emai : sounbunareth@yahoo.com